**OMI0013**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ញ៉ែម ឈីន ភេទប្រុស អាយុ៥៩ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ “យោធា”**

**សព្វថ្ងៃរស់នៅភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ខែសីហា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ផាត កុសល**

**០១:២៣:៤៨**

**៣៥ទំព័រ**

ឈីន : គេឲ្យធ្វើអីក៏ធ្វើក៏ធ្វើនឹងឯង គេឲ្យធ្វើទាហាន អារឿងប្រវត្តិសាស្ត្រគេប្រែបែរទៅម៉េចៗ អត់ដឹងទេណា៎ ។ បើនិយាយរឿងកម្រិត ប្រវត្តិដូរជត់ វាហួសៗនិយាយទៅហើយ វាមិនដឹងនិយាយម៉េចកើត ។

កុសល : ខ្ញុំចាប់ផ្ដើមសួរពីឈ្មោះលោកពូមុន ។ លោកពូឈ្មោះអីដែរ?

ឈីន : ញ៉ែម ឈីន ។

កុសល : មានឈ្មោះហៅក្រៅ?

ឈីន : អត់ទេ ។

កុសល : ថ្ងៃខែឆ្នាំកំណើត អត់មានឈ្មោះអីក្រៅពីនឹង?

ឈីន : អត់ទេ ។

កុសល : ថ្ងៃខែឆ្នាំកំណើត?

ឈីន : អឺ! ១៩០០ប៉ុន្មានទេ ភ្លេចទៅហើយ មិនបានជាចាំច្បាស់ទេ ។

កុសល : ប្រហែល លោកពូអាយុប៉ុន្មានឆ្នាំហើយឥឡូវ?

ឈីន : អាយុបែប៥៧ ៥៨ ៥៩ ។

កុសល : ៥៩?

ឈីន : បាទ!

កុសល : ចុះកើតនៅភូមិណា ស្រុកណា ខេត្តណា?

ឈីន : ដែលនៅស្រុកកំណើត?

កុសល : បាទៗ ។

ឈីន ៖ ភូមិសន្ទាត់ ។

កុសល ៖ ឃុំ?

ឈីន ៖ ក្រយា ស្រុកស្ទោង កំពង់ធំ ។

កុសល ៖ ចឹងសុំឲ្យលោកពូរៀបរាប់ពីជីវិតរបស់ពូៗ រំលឹកមុនឆ្នាំ៧៣?

ឈីន ៖ ជីវិតរបស់ខ្ញុំកាលពីខ្ញុំរស់នៅជាមួយឪពុកម្ដាយ គឺជីវភាពជាសិករសុទ្ធ រៀនសូត្រក៏មិនសូវបាន ពីព្រោះក្មួយឃើញស្រេចហើយពីជំនាន់នោះ សាលាក៏វាឆ្ងាយ គ្រូក៏វាក្រ កាលនោះអានោះនិយាយដែលខ្ញុំកម្រិតបានរៀន គឺសង្គ្រាមលន់ នល់ ចុះហើយរៀនគ្រូលោកទេ ។ ដល់ថ្ងៃព្រឹកលោកឆាន់បបរហើយចេះចូលបង្រៀន ដល់ម៉ោងល្ងាចសម្រាកចេញមកផ្ទះ ។ អត់ដែលបានចូលសាលាអីយើងណាសំងំសំណើរទេ ទៅរៀនលោក ។

កុសល ៖ ចុះលោកពូនៅចាំព្រឹត្តិការណ៍ពេលសម្ដេចឪត្រូវបានគេទម្លាក់ ធ្វើរដ្ឋប្រហារ ចាំថ្ងៃរដ្ឋប្រហារ?

ឈីន ៖ អត់ៗចាំបាន ព្រោះខ្ញុំនៅក្មេងដែរ ។

កុសល ៖ ថ្ងៃទីខែ៣ ឆ្នាំ៧០ រដ្ឋប្រហារ ពូនៅចាំទេ?

ឈីន ៖ អត់ចាំទេ ។

កុសល ៖ ចុះនៅចន្លោះឆ្នាំ៧០ ទៅ៧៣នឹងលោកពូធ្វើអីដែរ?

ឈីន ៖ ខ្ញុំ!

កុសល ៖ អឺ!កាលពូ៧០ ដល់៧៥ នៅនឹងដដែល?

ឈីន ៖ អូ! ខ្ញុំពី៧០ខ្ញុំនៅផ្ទះដែរ រហូតទៅដល់៧១ ទៅបានខ្ញុំចេញ ព្រោះគេតម្រូវហើយមិនដឹងធ្វើម៉េច គេចម៉េចផុត ចេញៗធ្វើទាហាន ។

កុសល ៖ អង្គការតម្រូវឲ្យធ្វើទាហាន?

ឈីន ៖ បាទ! អង្គការខាងក្រៅ ខាងនោះពីជំនាន់លន់ នល់ បើនិយាយទៅយើងថាខាងតស៊ូ ខាងខ្មែរក្រហម ។

កុសល ៖ អ! ខាងតស៊ូ គេមិនមែនហៅខ្មែរក្រហម គេហៅខាងតស៊ូ ខាងបដិវត្តន៍?

ឈីន ៖ ហ្នឹងហើយ ។

កុសល ៖ អាយុប៉ុន្មានពេលចេញទៅ?

ឈីន ៖ អាយុ១៩ ។

កុសល ៖ មើលទៅក្មេងៗមែនទែន?

ឈីន : នៅក្មេងៗ ដល់ខ្ញុំចេញទៅ ខ្ញុំវាលំបាកវេទនាវាលំបាកហើយ គិតទៅរបស់ថាយើងដើរគ្មានទីកំណត់បានចឹង ។

កុសល : គេស្នើទៅម៉េងពូ?

ឈីន : គេជម្រុញយើងដូចតាមមូលដ្ឋាន គេជម្រុញមិនឲ្យយើងនៅយើងជាយុវជន វាត្រូវទៅបម្រើជាតិៗ បើនៅក៏វានៅមិនបានសុខដែរ គេមិនឲ្យយើងនៅទេៗ ចុះហើយបើយើងចេះតែនៅក៏វាអត់កើត នាំគេមើលងាយ មើលថោក មនុស្សជាកូនប្រុសនឹងគេដែរ ។

កុសល : ដល់ពេលនឹង ពួកអាមេរិចមានទម្លាក់គ្រាប់បែកទៅលើភូមិឃុំយើងទេជំនាន់នឹង?

ឈីន : អូ មកជួបភូមិខ្ញុំ អត់ដែលប៉ះទេ ប៉ះខាងតាំងក្រសាំងនោះ ព្រោះភូមិខ្ញុំនៅព្រៃច្រើនដែរនោះ ហើយតំនប់ទូលាយខ្លាំងណាស់ ។ ទៅខាងតាំងក្រសាំងបានទម្លាក់ច្រើនៗ ទៅខាងខ្ញុំអត់ទេ ទម្លាក់មួយដួរនេះ ខាងកើតអន្លង់ក្រាញ់នោះ មកនេះភ្លេចអាភូមិនៅជិតៗ ។

កុសល : ពេលចូលទ័ពបដិវត្តន៍ អាយុ១៩ឆ្នាំនឹង ពូអត់ដឹងថាចូលដើម្បីអីទេ ដូចថាចេះតែចូល គេឲ្យទៅចេះទៅ?

ឈីន : ទៅ ប៉ុនចូលគេចូលដឹងថាន័យថាគេតស៊ូរំដោះៗជាតិ ឲ្យផុតពីពួកនាយទុន ពួកជិះជាន់ខ្ញុំដឹងតែប៉ុននេះ អត់ដឹងតាបិចតាប៉ុកយ៉ាងណាទៀតអត់ទេ ។ គេគ្រាន់តែប្រាប់ប៉ុនោះ គេបំភ្លឺឲ្យយើងដឹងស្មារតីថាយើងជាកសិករ យើងមិនចេះល្ងង់ខ្លៅទៅ គេចេះតែជិះជាន់ រឹបអូសតាំងពីកមាំងពលកម្ម ជិះជាន់តាំងពីដីស្រែដីធ្លីណាណា ។ ចុះរបស់ចុះគេចេះតែថាដល់យើងមិនសូវចេះដែរ ។

កុសល : កាលនឹងប្រធានភូមិគេចុះមក ឬក៏ខាងទាហានគេចុះមក ឬក៏ខាងគណៈស្រុកគេចុះមក?

ឈីន : មានអាវុធឃោសនាគេ ។

កុសល : គេមានអាវុធឃោសនាគេ?

ឈីន : បាទ! អាវុធឃោសនា ស្នាលទោសដូចក្មួយឯង មានក្រសួងការងារពីនោះមក គេទម្លាក់ម៉ាក្រុម ចែក៣ៗនាក់តាមភូមិចឹង គេមកបង្រៀនយើងយល់ ។

កុសល : ចឹងគេមកពន្យល់ឲ្យចូលចឹងទៅ?

ឈីន : បាទ! យើងចេះចុះទៅ ជាកូនប្រុសដើមទ្រូង៥ហត្ថ ចុះធ្វើម៉េចយើងត្រូវតែតស៊ូ គេមកបង្រៀនៗ ប៉ុនពួកនោះអត់ចង់បានអីទេ ។

កុសល : ហើយចុះអ្នកភូមិជិតខាង ហើយយុវជនជំនាន់ពូដូចថាគ្រប់គ្នាចូលសស្រាក់សស្រាំ?

ឈីន : អូ! អស់ បើអ្នកខ្លះមិនបានធ្វើទាហាន ក៏ធ្វើជាកងផលិតខាងទន្លេសាប ខាងអីនោះ ។

កុសល : ចូលអស់?

ឈីន ៖ អស់ អត់មាននៅទេ ។

កុសល ៖ ហើយក្រោយមកគេបញ្ជូនទៅវ៉ៃពួកលន់ នល់ នៅម្តុំណាទៅ?

ឈីន ៖ ខ្ញុំកាលនោះខ្ញុំចូលទៅ ខ្ញុំទៅរៀននឹងឈូក ២ថ្ងៃ ។

កុសល ៖ គេឲ្យរៀន២ថ្ងៃ?

ឈីន ៖ បាទ! ២ថ្ងៃបានទៅកើត ខ្ញុំទៅវ៉ៃកំពង់ចាម ។

កុសល ៖ ហើយចុះតែ២ថ្ងៃចេះដែរ រៀនចេះបាញ់អាវុធបាញ់អី?

ឈីន ៖ អត់ទេ មើលគេៗមិនទាន់បានរៀនបច្ចេកទេសអីទេ លួចមើលគេខបមាថា គេបង្ហាប់ថា ដោះកាំភ្លើងរបៀបនេះរបៀបនោះ គ្រាន់តែសំលឹងលួចមើលគេបណ្តោយទុកក្នុងចិត្ត គំនិតខ្លួនឯង តែប៉ុននេះ ។

កុសល ៖ តែ២ថ្ងៃ ឲ្យទៅម៉ង ចូលទៅសមរភូមិមុខ?

ឈីន ៖ ឲ្យទៅគេសួរដែរ សួរថាប្អូនឯងហ៊ានទៅជាមួយគេទេ? បើគេទៅៗ ។ បើមិនទៅម៉េចគេទៅហើយ គេរត់ៗនឹងគេ ។ និយាយពីដល់ក និយាយពីរត់មកវិញ ចូល៥០នាក់ចេះ តិចរត់មកវិញបាត់អស់ ៣-៤-១០ថ្ងៃ ដែលឃើញទៅវិញអីត ចូលទៅមិនចេញស្មើ មិនធម្មតាទេកាលនោះ យើងបាច់ទឹកដាក់គ្នា ។ ផ្សារកំពង់ចាម ។

កុសល ៖ វ៉ៃនៅកំពង់ចាម?

ឈីន ៖ ហ្នឹងហើយ អាដើរទៅ១០នាក់ចេះ មកវិញតែ៦-៧នាក់ទេ ។

កុសល ៖ ស្លាប់ច្រើន សឹងពាក់កណ្តាល?

ឈីន ៖ យី! និយាយមិនច្រើនម៉េច បើចូលចិត្តសំបុកទៅហើយនោះ ។

កុសល ៖ ចុះពួកលន់ នល់ ស្លាប់ច្រើន?

ឈីន ៖ នោះឯង ។ រឿងនោះមិនធម្មតាទេ នៅម៉ាកន្ទែង ប៉ុនខាងក្រោគេចល័តផងនៅតែងាប់ចូលទៅដល់មុខរោងកុនហើយ មានរឿងអី ។

កុសល ៖ ចុះពូមានដែលទទួលមេដៃអី?

ឈីន ៖ អត់ៗទេ ។

កុសល ៖ អត់បានទទួលទេ?

ឈីន ៖ គេគ្រាន់ វាមិនមែនជាមេដៃសក្តិយស មិនមែនជាស្អី ប៉ុនគេឃើញយើងទៅហើយ បើថាយើងធ្វើស្រែ ធ្វើឲ្យវាអស់ចិត្ត ទៅធ្វើសមភ្នែកប្រមុះគេឯងផង ហើយមេផង ប្តូក៏យើងមានលទ្ធភាពអាចទៅបានត្រឹមមេក្រុមទេ មានសិទ្ធិក្រុមការនោះ១២នាក់ ប៉ុន្តែសិទ្ធិបញ្ជាបាន ស៊ើបការណ៍បាន ប៉ុនវាមិនមានអីជាស្លាកស្នាមដើម្បីអីទេ ។

កុសល ៖ ពូមានរបួសមានអីទេ?

ឈីន ៖ អត់ទេ ទើបមករបួសនឹងនេះ របួសយើងនឹងជិតយួនចូលស្រុកហើយទេ នៅនេះយើងនៅថៃ។

កុសល ៖ នៅថៃវិញ?

ឈីន ៖ បាទ!

កុសល ៖ ដល់ពេលជំនាន់ដាមួយលន់ នល់ អត់មាន?

ឈីន ៖ អត់ទេ។

កុសល ៖ ចុះដូចក្រុម១២នាក់នឹង មានស្លាប់ច្រើនទេ ក្នុងក្រុមរបស់ពូដែលពូកាន់បញ្ជា មានស្លាប់ច្រើន?

ឈីន ៖ អឺ! រត់មួយប្រឹប បើគិតទៅវាសឹងនឹងអស់ ព្រោះដែលស្លាប់ទៅថែម១។

កុសល ៖ ជូនបន្ត?

ឈីន ៖ បាទ! ជូនបន្ត ដល់យូរ១ភ្លេចបាត់។

កុសល ៖ ចេះតែមានមិនចេះខ្វះមកចូល?

ឈីន ៖ អឺ!ដូចខ្ញុំថា ដែលគេបញ្ជូនពីក្រោយទៅ ដល់ទៅដល់បែកកងពល។ ដល់ដាក់កន្លែងកងពល គេស៊ីលេងរួចគេប្រជុំម៉ាព្រួសគេបំបែកជាសាខា ជលវរសេនាធំ១គេបែកទៅវរសេនាតូច១ បែកកងធំ កងតូចទៀតចេះ។

កុសល ៖ គេមានបំពាក់ពីបញ្ហាគោលជំហរនយោបាយ កាលនឹងគេមានបង្រៀនទ្រឹស្ដីនយោបាយ?

ឈីន ៖ បង្រៀនពន្យល់ ខបមាមួយថ្ងៃ២ថ្ងៃ មួយស្នាក់ចឹងចូលបង្រៀនទៅ ឲ្យបានរៀនមួយអាទិត្យ ពីរអាទិត្យ អត់ទេ។

កុសល ៖ ថ្ងៃ១៧ មេសា ឆ្នាំ៧៥ លោកពូនៅណា ពេលនឹងមានអារម្មណ៍ម៉េចដែរ រំដោះ?

ឈីន ៖ នែក! ថ្ងៃនោះ គឺខ្ញុំនៅស្រុកអូរក្នុងខេត្តនេះឯង ឧត្ដរមានជ័យ។

កុសល ៖ មកដល់ឧត្តរមានជ័យ?

ឈីន ៖ ពីព្រោះខ្ញុំនៅនេះឯង ប៉ុន្តែខ្ញុំមិនបាននៅខាងក្រោមទេ ខ្ញុំនៅឈ្លបក្រៅប្រទេស។

កុសល ៖ ថាម៉េចឈ្លបក្រៅប្រទេស?

ឈីន ៖ ឈ្លបក្រៅប្រទេសគឺ ព្រំដែនគឺសម្រាប់ការពារព្រំដែន និងវ៉ៃយកតំបន់ភ្នំនេះ។

កុសល ៖ ចឹងលោកពូគេបញ្ជូនមកការពារយកតំបន់ព្រំដែន?

ឈីន ៖ បាទ!

កុសល ៖ ជំនាន់នឹងអ្នកណាគ្រប់គ្រង តំបន់ព្រំដែន?

ឈើន ៖ ព្រំដែនកាលនោះតា ម៉ុក នេះឯង តាទែម ខ្មោចតាទែម នឹងមុខសញ្ញាមួយចំនិតត្រង់នេះ ។

កុសល ៖ ហ្នឹងឆ្នាំ៧៥ ?

ឈើន ៖ បាទ! ៧៥ហើយ ។

កុសល ៖ ហើយចុះពួកទាហានថៃពេលនឹងយ៉ាងម៉េចដែរ ពេលមកដល់ព្រំដែន ពូឃើញអីខ្លះ ពួកទាហានថៃសហការជាមួយយើង?

ឈើន ៖ អត់ទេ អត់មានរឿងអីសហការទេ ។

កុសល ៖ ពូរៀបរាប់ព្រឹត្តិការណ៍ពេលនឹងនៅចាំបានទេ ពេលមកជួបដល់ព្រំដែន តំបន់ព្រំដែននឹងយ៉ាងម៉េចខ្លះ?

ឈើន ៖ ពីព្រោះបានខ្ញុំថាវាអត់មានពិភាក្សាអី ពីព្រោះគោលការណ៍ខាងនេះ គឺថារំដោះទឹកដី គេថារំដោះយកភ្នំដងរែកដីយើង រហូតពីជំនាន់ណានោះ ជំនាន់ព្រៃចេកព្រៃអីនោះចេះ ។

កុសល ៖ ថាជារបស់យើង?

ឈើន ៖ ជារបស់យើង ចុះហើយឈប្រៅប្រទេសនោះ ពេលគេរើសមិនមែនចេះតែយកទេណាបើថាមេក្រុមក៏សំនិដែរ យុទ្ធជនៗអស្ចារ្យបានគេយកៗ ។

កុសល ៖ បានគេយកមកការពារប្រទេស ការពារព្រំដែន?

ឈើន ៖ បាទ! អាខ្សែត្រៀមក្រុមនៅដូចយើងសព្វថ្ងៃនេះ តាមកន្លែងៗ តែឈប់នោះ១ក្រុម១២រយៈកាលប៉ុននេះមួយក្រុមដូរឡើងគោកមិញមួយក្រុមទៀត នៅតាមបុសជំឡូង ។

កុសល ៖ ចឹងជំនាន់នឹងមានឃើញទាហានថៃ នៅតាមនឹង?

ឈើន ៖ ឃើញ វ៉ៃគ្នាតើ ។

កុសល ៖ ច្រើនប្រាលវ៉ៃជាមួយថៃពេលនឹង?

ឈើន ៖ យី! មើលគិតទៅច្រើនដែលណា ។

កុសល ៖ នៅឆ្នាំ៧៥ ពេលយើងរំដោះភ្នាម?

ឈើន ៖ អាគេរំដោះភ្នាមក្តុងក្តាំងរហូតខ្ញុំអត់ទាន់ចុះទេណា ទាល់តែទាហានយួន និងខ្មែរនៅដល់នេះបានខ្ញុំចុះពីលើ ខ្ញុំនៅតែនោះ ។

កុសល ៖ ការពារព្រំដែន?

ឈើន ៖ បាទ! មានឃ្លាំងអន្លុរត្រីធៀតអីទុកតាមកន្លែង តាមក្រុមស្រេច ។

កុសល ៖ ចុះបន្ទាប់មកទៀត ពូថាពី៧៩រហូតដល់ថ្ងៃពួកយួនចូលមក ពូនៅនឹងដែរ?

ឈើន ៖ នៅនឹង ។

កុសល ៖ ចឹងពេលនឹងពូឲ្យគេទទួលខុសត្រូវធ្វើអីខ្លះ?

ឈឹន ៖ កាលនោះ ។

កុសល ៖ បាទ! បន្ទាប់មកទៀត បន្ទាប់ពីគេរំដោះហើយ?

ឈឹន ៖ គេរំដោះ គេអត់ទាន់នេះនឹងរំដោះហើយ៧៥ ៧៦ ៧៧ រហូតដល់៧៩ខ្ញុំមិនធ្វើអីទេ ត្រឹមកងធំ កងតូចនោះឯង ។

កុសល ៖ យើងកាន់កងពលធំ?

ឈឹន ៖ អត់ទេ គ្នា៤-១០-២០នាក់ ៣០នាក់នឹង ៤០នាក់ ។

កុសល ៖ អានឹងជាកងហា កងរយនឹង?

ឈឹន ៖ បាទៗ ចុះឯង ។

កុសល ៖ កងហា កងរយ?

ឈឹន ៖ កងហា ។

កុសល ៖ ហើយគេឲ្យការពារព្រំដែនជិតទាន់នឹង ។ ពេលក្រោយមកទៀត ជីវភាពរស់នៅពេលនឹង យ៉ាងម៉េចដែរនៅតាមក្រុមៗទាហានរបស់ពូ ញុំបាយ ឲ្យញុំគ្រប់គ្រាន់?

ឈឹន ៖ ទេ! បើសណ្ដាប់ធ្នាប់ទាហានអត់មានបញ្ហា គេយកចិត្តទុកដាក់ ។

កុសល ៖ យកចិត្តទុកដាក់ខ្លាំង?

ឈឹន ៖ បាទ! តែសន្ទឹកទៅខាងមូលដ្ឋានទេ មានថាអត់បាយអត់ទឹកអី តែចំពោះខ្មែរត្រៀមលេ ប្រជាជននៅអែបៗជើងភ្នំក៏អត់មានបញ្ហា ព្រោះអត់ហ៊ានធ្វើដោយសារមានទាហាននៅ ច្រើន ។ ទាហានប្រៀបដូចសំណាក់ទៅធ្វើការទៅ ពេលសម្រាកក៏ចុះមកក្រោមមក ។ មក រៀនមកសូត្រនៅក្រោម ។

កុសល ៖ ការបំពាក់បំប៉នយោបាយនឹងគឺច្រើនៗទេ ញឹកញាប់ទេ?

ឈឹន ៖ ទេ!មានអីផ្លាស់ប្ដូរគ្នារាល់ខែដែលនឹង ជួនណាក្នុងខែនេះខ្ញុំមក១០ថ្ងៃ ឬ៧-៨ថ្ងៃឡើងទៅ វិញ គេមកម្ដង ។

កុសល ៖ អ្នកណាគេ ដូចលោកសុន សេន ជារដ្ឋមន្ត្រីក្រសួងការពារជាតិ?

ឈឹន ៖ បាទៗ ។

កុសល ៖ ចង់អ្នកគ្រប់គ្រងតាមការពារតំបន់នឹង ក្រោមបន្ទុកអ្នកណាគេ?

ឈឹន ៖ ក្រោមបន្ទុកលោកសុន សេន, ខៀវ សំផន ។

កុសល ៖ ចុះក្រោមបន្ទាប់?

ឈឹន ៖ ក្រោមបន្ទាប់អស់លោកកាលនោះនៅលិច ។

កុសល ៖ ចុះមេផ្ទាល់របស់ពូ ជាអ្នកណាគេ ដែលគ្រប់គ្រងនៅតាមតំបន់ការពារព្រំដែន មេបន្ទាប់ លើៗ?

ឈីន ៖ អូ! មេខ្ពស់ជាងគេកាលនោះ កងពល តា ទែម ប៉ុនស្លាប់បាត់ហើយ ។

កុសល ៖ ចុះអ្នកណាខ្លះដែលគាត់នៅរស់?

ឈីន ៖ អឺ! ទៅលិចក៏ ។

កុសល ៖ តំបន់នឹងគេហៅតំបន់អី កាលជំនាន់៣ឆ្នាំ?

ឈីន ៖ កាលនោះភូមិភាគ៤ ។

កុសល ៖ លោកពូដែលឃើញថា មេដឹកនាំជំនាន់នឹង គាត់មកត្រួតពិនិត្យដែរ ដូចថាសុន សេន ដូច ជា តាម៉ុកអី គាត់ចុះមកជួយណែនាំរបៀបការពារជាតិ ការពារប្រទេសម៉េចដែរ?

ឈីន ៖ ទេ! ដែលឃើញដែល យូរៗគាត់មកម្ដងតាមរយៈផ្លូវក្រោម ។

កុសល ៖ អ្នកណាមក?

ឈីន ៖ ជួនណាតា? ជួនណាអ៊ំ នួន ជា ។

កុសល ៖ នួន ជា គាត់មកដែល?

ឈីន ៖ បាទ!

កុសល ៖ គាត់មានណែនាំអីខ្លះ?

ឈីន ៖ ណែនាំពន្យល់ចុះ ។

កុសល ៖ សុន សេនក៏ចុះដែរ?

ឈីន ៖ អឺ!

កុសល ៖ ចុះតាម៉ុកគាត់ចុះមកដែរ?

ឈីន ៖ តាម៉ុកគាត់ញឹកជាងគេ ព្រោះគាត់អ្នកសមរភូមិ ។

កុសល ៖ ប៉ុន្តែគាត់នៅខាងភូមិភាគនិរតីជំនាន់នឹងមែនទេ?

ឈីន ៖ ទេ! ខ្ញុំព្លងនោះឯង ខ្ញុំទើបមក៧៥ ៧៦ ៧៧នឹងបានឃើញ ពីដើមមិញដឹងតាមរយៈ លោកនេះលោកនោះ មិនដែលឃើញទេ ។

កុសល ៖ ៧៧ហើយបានជួបឃើញតាម៉កចុះមក?

ឈីន ៖ បាទ! ដែលគេធ្វើកន្លែងទីស្នាក់ការធំយើងនៅដែលមុតខាងនោះ ។

កុសល ៖ ចុះសុន សេន, នួន ជា គាត់ចុះមកញឹកទេ?

ឈីន ៖ គាត់មកនោះឯង គាត់ធ្វើស្នាក់ការកន្លែងដឹកសម្ភារៈ មិនតិចទេ ។

កុសល ៖ ចុះពូចាំបានទេ ពេលពួកវៀតណាមចូលមក ជំនាន់នឹង?

ឈឺន ៖ អត់ចាំបានថ្ងៃ ។

កុសល ៖ តើវាចូលមកមានសភាពប្រែប្រួលយ៉ាងម៉េចខ្លះពេលនឹង?

ឈឺន ៖ ទេ! ខ្ញុំអត់ដឹងទេ គ្រាន់ឮស្នូរកាំភ្លើងឡើងជិតៗ បានបើរ៉ាដ្យូបាន ចុះខ្ញុំដូចថានៅតែលើ ។

កុសល ៖ អត់ដឹង?

ឈឺន ៖ អត់ដឹង ។

កុសល ៖ ហើយមានឃើញគេច្រើន ប្រជាជនចូលមកច្រើន?

ឈឺន ៖ អត់ ។

កុសល ៖ គេរត់ជម្លៀសចេញមកខាងនេះ មេធំប៉ុន្មាននាក់?

ឈឺន ៖ អត់ៗទេ ទាល់តែឃើញៗគេមកដល់ហើយ ខ្ញុំចុះមកដូចថាចេះឯង ។

កុសល ៖ ហើយឃើញជួប ឃើញ តា ម៉ុក ឃើញអី?

ឈឺន ៖ ជួបសួរគេ ។

កុសល ៖ ចុះ ប៉ុល ពត ដែលឃើញ?

ឈឺន ៖ អ! និយាយឲ្យត្រង់ ខ្ញុំបើថានៅនេះមែន ខ្ញុំមិនដែលទាន់ឃើញមុខ មួយប៉ុនសរសៃរសក់ ក៏មិនដែលឃើញមិន ។ ទោះបីជាកាលមុនគាត់នៅនេះ ខ្ញុំនៅតាមនេះដែរ ក៏មិនដែលហ៊ាន ទៅជិតទៅអីអត់រលីង ។

កុសល ៖ ខ្លាចទេ?

ឈឺន ៖ ទេ! មិនខ្លាចទេ គេមិនចេញបង្រៀនឲ្យឃើញ ឬក៏គេមកលេងអីចេះចុះតាមរយៈមេមក កន្លែងកងពល ឬកន្លែងភូមិភាគអី នេះអត់ទេ ។ គេនៅតែគេ ប្រពន្ធគេ ហៅតែមេធំៗទៅរៀនសូត្រក៏ទៅតាមរយៈគេណែនាំយើងប៉ុននោះឯង ។ យើងមិនដែលចុះជាប់ ដូចតាម៉ុក ជួនណាគាត់មកង្រៀនខ្លួនគាត់ផ្ទាល់ នួន ជា គាត់ថាចង់មកឡើងមកហើយប្រុច មក បង្រៀនឲ្យឃើញភ្លាម កាលនោះអត់ឲ្យអ្នកណាឃើញទេ ។

កុសល ៖ គាត់លាក់មុខម៉ង?

ឈឺន ៖ អត់ឲ្យឃើញមែន ខ្ញុំអត់និយាយកុហកទេ ។

កុសល ៖ ទម្លាប់គាត់ចឹង?

ឈឺន ៖ ខ្លាចមន្ត្រីគេធំៗ ខ្លាចគេឃើញ ត្រឹមវរសេនាតូចស្អែកបានឃើញ ។ ទៅរៀនៗត្រឹមបង តំណាងទី២ ទី៣ ពីគាត់ទៅទៀត ។

កុសល ៖ តែលោកពូធ្លាប់បានឃើញ តា ម៉ុក?

ឈឺន ៖ កាលនោះថឺមិនឃើញ ញឹកៗគ្រាន់ ។

កុសល : គាត់ឧស្សាហ៍ណែនាំអីខ្លះពូ ព្រោះឃើញគាត់សង់ផ្លូវសង់អីច្រើន ជំនាន់គេចុះមុនសមាហរណកម្ម តាំងពីជំនាន់៨០មក?

ឈីន : ខ្ញុំទៅសួរលេងដែរតើដឹងថាម៉េចទេ បើស្រុកនៅសង្គ្រាមចេះឲ្យវៃប្រទូសប្រទាំងពេញវាល បើយើងឈ្នះគេទៅគ្រាន់ បើគេឈ្នះយើងតាង ឡានចំនាយលុយមិនស្មើរ ទៅធ្វើឡើងកំប៉េះខាតទេតា? ហ៉េ!ឯងទៅខ្វល់អី អញធ្វើផ្លូវអញនោះ ឯងមកបើឯងមិនចេះដើរៗ ផ្លូវដើរក្នុងព្រៃដើរទៅ គាត់ថាចឹង ។ ស្ពាន ទំនប់ៗអញ ។

កុសល : អាទំនប់លើនេះ?

ឈីន : នេះអាទំនប់នឹងស្ពានយើងនេះ ។ វាមិនចេះដើរ វាហែលទឹកហែលទៅ ដែលចៀសទៅរួច ផ្លូវអញមនុស្សនៅ ថាតែនោះឯង គាត់ចេះតែធ្វើ ។

កុសល : គិតទៅគាត់កសាងបានច្រើនដែរ?

ឈីន : គ្រាន់ៗដែរ អន្ទង់វែង ។

កុសល : ពូយល់ថា គាត់ជាមនុស្សស្នេហាជាតិល្អ?

ឈីន : មានដឹងដែរតើ ដឹងតិចៗ គាត់ធ្វើខាងនេះមែន តែខ្ញុំមិនដឹងថាធ្វើម៉េចមិនដឹងអី នៅតែវិលទាន់រហូតដល់ជិតចុះសមាហរណកម្ម ។ គាត់ថាជិះឡាន គាត់ថា ពួកឯងកុំឆោលលោពេក អញរក បុណ្យឲ្យពួកឯងមាន ។ ឯងចង់ឈប់ផ្អែក អញឲ្យឈប់ផ្អែកហើយ ។ ចង់ឯករាជ្យខាងស្អែក អញឲ្យឯករាជ្យខាងស្អែក ប៉ុនអញរកក្រឡាដើម្បីឲ្យគ្រាន់ ពីព្រោះយើងចេញយូរហើយ វាអស់ចានអស់ឆ្នាំងហើយ ។ មិនងាយដូចគេដែលគេនៅក្នុងជ្រៅៗទេ ឯនោះបានគេចានឆ្នាំងលុយកាក់គេសន្សំយូរហើយ គេមិនដែលរត់ គេមិនដែលផ្អើលមិនដែលភ្ញាក់ អានោះបានគេមានគោមានក្របី ។ នៅមិនទាន់បាន៣-៤ខែផងក៏ ។

កុសល : មានអ្នកផ្តាច់ខ្លួន?

ឈីន : ផ្តាច់អី ។

កុសល : គាត់ស្លាប់?

ឈីន : អត់ស្លាប់ទេ មិនទាន់ដឹង៣-៤-៥ខែ មានក្តីទាក់ទងគ្នាចរចាខាងជើងត្បូង ។

កុសល : ហើយពេលនឹងយ៉ាងម៉េចដែល ពេលដែលការចរចានឹង មានអ្នកផ្តាច់ខ្លួន?

ឈីន : មាន អាខ្លះគេបន្ទាប់ខ្លាំងក៏គេមកមុនទៅ ។

កុសល : ដូចតាពឹមអី?

ឈីន : នឹងហើយ ។

កុសល : ពូស្គាល់គាត់ដែរតើ នៅជាមួយគ្នា?

ឈីន ៖ តាពឹម ភឹមស្គាល់ ។

កុសល ៖ ចុះពូកាលនឹងវរសេនាតូចរបស់ពូនៅក្រោមគាត់ដែលអត់ទេយ៉ាងម៉េច?

ឈីន ៖ អ! មុនឆ្ងាយណាស់ ។

កុសល ៖ ចុះពូមកមុនជាមួយគាត់ ឬមកក្រោយ?

ឈីន ៖ អូ!ខ្ញុំមកក្រោយគេបង្អស់ ពីព្រោះខ្ញុំថាតែទៅត្រង់ណាគ្នាច្រើនគឺមិនដែលងាប់ទៅទាំងកំប្លេរម៉ង ហើយចាំមើលអ្នកណាឡេឡូ ដួនណារត់មកប៉ះសុខសប្បាយៗ ប៉ះមិនសុខសប្បាយទ័ពងាប់ ឬវាអី ។ វាដូចមិនមានអីមែន ដែលថាខ្ញុំមកនេះ ។

កុសល ៖ ចឹងលោកពូមកជំនាន់តាពឹមនឹង ឬជំនាន់បងជាណា?

ឈីន ៖ មកក្រោយ ។

កុសល ៖ ហេតុអីក៏មិនមកជាមួយគេខាងនឹង?

ឈីន ៖ ចុះកាលនោះពួកគេនៅខាងនោះផ្សេង ដូចថាមួយកងគេឈុតគេផ្សេង ។

កុសល ៖ តែក្រុមគ្នាគេ?

ឈីន ៖ ក្រុមគ្នាគេទៅ ដល់យើងនេះមិនដឹងអីដែរនៅទៅ ។

កុសល ៖ នៅជាមួយតាម៉ុក?

ឈីន ៖ នៅនេះទៅ ចឹងហាំ ។ គេៗមិនហ៊ានមកខ្សឹបប្រាប់តស់ទៅចេះចុះ ហ៊ានឲ្យមេលើគេដឹងគេដាក់ក្បាលងាប់នោះ ថាចុះ បើថាបានជួបគ្នាលួចស៊ីសុះវែងឆ្ងាយ ។ ដែលមានពេលដើរលេងប៉ុន្មាន អត់ទេ ។

កុសល ៖ តាម៉ុក គាត់អត់ដឹងទេ ពេលនឹងគាត់អត់ដឹងថាមានអ្នកលួចផ្តាច់ខ្លួនទេ មេៗលើអត់ដឹង?

ឈ់ន ៖ មិនដឹងទេ ។

កុសល ៖ ចុះក្រោយគាត់ដឹងម៉េច គាត់ឆេវ ប្រឡោតខ្លាំងម៉េច យ៉ាងម៉េច?

ឈីន ៖ ចុះខឹងៗមួយសន្ទុះទៅចុះ មិនជាអីប៉ុន្មាន តា ម៉ុក គាត់ខឹងខ្លាំង ។ ថ្ងៃដែលចេញអូសកម្លាំង តាមវៃព្រួសពេញព្រៃ មានអីអត់ អត់ឃើញកម្លាំងទៅតាមវៃណា ទៅម៉ូតូ ។

កុសល ៖ ទាក់ទងទៅនឹងដូចថាពេលដែលលោកពូចូលមក បន្ទាប់ពីសមាហរណកម្ម៩៨ ពេលនឹងមកគេឲ្យលោកពូទៅធ្វើទាហានតទៅទៀត ឬក៏យ៉ាងម៉េច? បើតាមខ្ញុំដឹង យើងនៅបន្តសក្តិដដែល ។

ឈីន ៖ ខ្ញុំកាលនោះខ្ញុំនៅធ្វើនៅឡើយ ប៉ុន្តែខ្ញុំ ។

កុសល ៖ គេឲ្យឋានៈអី ដែលកាលនឹងពេលចូលមក?

ឈីន : អត់ទេ ខ្ញុំឈប់ហើយ គេឲ្យគ្រាន់នៅជួយពង្រឹងឈប់បន្តិចៗ ខ្ញុំសុំគេឈប់តែម្តង ព្រោះខ្ញុំដើរយាប់ ព្រោះកាលនោះដើរមិនធម្មតាទេ ដើរពីនេះទៅនោះ ដើរទាំងយប់ក៏ដើរទាំងថ្ងៃ ត្រូវយប់ដើរក៏ដើរ ត្រូវថ្ងៃក៏ដើរ ហើយខ្ញុំសុំគេឈប់ ។

កុសល : ពូនៅសុខភាពមាំមួន មើលឃើញជាងពូមេភូមិអី គាត់រៀងទ្រុនដល់ហើយ គាលត់ ។

ឈីន : សុំឈប់ ទម្រាំបានគេឲ្យឈប់ឡើងយូរមែនទែន ។

កុសល : ហេតុអីបានសម្រេចចិត្តសុំឈប់ ឆ្អែតហើយ ឆ្អែតនឹងសង្គ្រាម?

ឈីន : ឆ្អែតខ្ញុំឆ្អែត ម៉េចគេថាធ្វើកន្លងមកទៅមិនបានធ្វើអីក៏ដោយ យើងជាមនុស្សចាស់ទុំ យើងអត្តចរិតនឹងនរ គ្រាន់តែទៅបានប្រាក់ខែប្រាក់អីលុយគេកាត់រំសាយ ។ អូ! លុយត្រង់ណាលុយទៅ ខ្ជិលខ្វល់ខ្វាយ ថាចេះឯង បានប៉ុនណាហូបប៉ុននោះ រកខ្លួនឯងបានប៉ុននោះដេកប៉ុននោះ ។ ខ្ញុំលែងទាហាន មិនមែនថាទាហាននេះក៏ដឹងថាណាដឹង ឲ្យតែក្បួនទាហានហើយ ឆ្អែតហើយខ្ញុំឆ្អែត ។ សប្បាយនេះសប្បាយដែលចាយលុយគេទេ ឃើញលុយគេធ្លាក់មកទាំងគីប ញញឹម បានទៅដល់ដាក់ផ្សារ ដាក់កន្ទែងកាវ៉ាអូខេ សប្បាយណាស់ ។ ចាំមើលដល់គេត្រូវការវិញ ហើយពួកឯងនេះមិនធម្មតា ប្រហែលរត់ចោលសមរភូមិអស់ យើងគិតអា១០ថ្ងៃ អា១ខែ អា៣ខែនេះ គេអត់មានប្រើអីទេ គេប្រើឲ្យមកធ្វើការនៅមន្ទីរអីទេ ។

កុសល : ចុះឥឡូវពូសប្បាយចិត្តជាងមុន ធ្វើចំការនៅមើលចៅ?

ឈីន : មានអី ខ្ញុំ ។

កុសល : ពូរៀបការឆ្នាំណា?

ឈីន : ឆ្នាំ៨១ ៨២ដឹង ។

កុសល : ក្រោយនេះហើយ?

ឈីន : ចុះទើបកូន៥ ។

កុសល : កូន៥ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន? ហើយធ្វើម៉េចជួបអ្នកមីង ជួបគ្នានៅណា នៅតំបន់នេះធ្វើម៉េចមុនដំបូងបានជួបគ្នា?

ឈីន : គេក្រោម ធ្វើការក្រោម ។

កុសល : គេគំរូងឲ្យយើងរៀបការជាមួយគ្នា ឬក៏លោកពូជ្រើសរើស?

ឈីន : អត់ទេ ខ្ញុំរើសខ្លួនឯង ។

កុសល : ជួបគាត់ដោយចៃដន្យ?

ឈឺន ៖ បាទ! អត់មានទៅម៉ែឪណា ព្រោះខ្ញុំម៉ែឪក៏នៅឆ្ងាយ មិននៅឆ្ងាយសព្វថ្ងៃទេ សព្វថ្ងៃអស់ហើយខ្ញុំ ងាប់អស់ហើយបងៗក៏ងាប់អស់ យីអ្នកនៅផ្ទះអីក៏អាយុថ្លៃម៉េចៗ

កុសល ៖ ហេតុអីបានគាត់ស្លាប់? គាត់នៅខាងក្រោម?

ឈឺន ៖ ហ្នឹងៗ

កុសល ៖ លោកពូថាឪពុកម្ដាយ បងប្អូន ស្លាប់អស់?

ឈឺន ៖ ស្លាប់អស់ៗ

កុសល ៖ ហេតុអី?

ឈឺន ៖ គាត់ស្លាប់នឹងជម្ងឺស្លាប់នឹងអីៗ

កុសល ៖ ជំនាន់ហ្នឹង ជំនាន់៣ឆ្នាំ?

ឈឺន ៖ ជំនាន់៣ឆ្នាំស្លាប់អស់ម្នាក់ ខ្ញុំមកផុតហើយៗ

កុសល ៖ ចឹងអ្នកនៅក្រោយវេទនា?

ឈឺន ៖ អឺ! ស្លាប់អស់រលីងហើយនៅតែក្មួយ មិនដឹងប៉ុនណា អាខ្លះបានកូនអាខ្លះអត់ ខ្ញុំមិនដែលបានទៅទេសព្វថ្ងៃៗ

កុសល ៖ ចឹងតាំងពីលោកពូដែលចេញពីភូមិមកនឹង គឺអត់ដែលបានត្រឡប់ទៅវិញទេ?

ឈឺន ៖ អត់ទេៗ

កុសល ៖ ហើយអត់ដែលបានជួបឪពុលម្ដាយ?

ឈឺន ៖ អត់ទេៗ

កុសល ៖ ហើយពូយល់ម៉េចដែលចឹង?

ឈឺន ៖ មិនដឹងយល់ម៉េច ពីព្រោះអីខ្ញុំយល់ថាៗ

កុសល ៖ មានអារម្មណ៍ម៉េច ឥឡូវចឹង អត់ដែលបានជួបឪពុកម្ដាយ?

ឈឺន ៖ ខ្ញុំទៅលេងទៅដូចថាវាអស់ទីលំនឹងៗ

កុសល ៖ លោកពូចូលនិវត្តន៍ទៅព្រៃនឹង ពេលឆ្នាំណាពូត្រឡប់ទៅស្រុកវិញ ទៅរកឪពុកម្ដាយវិញ?

ឈឺន ៖ អត់ដែលបានទៅរហូតមកដល់ថ្ងៃនេះៗ

កុសល ៖ ចឹង?

ឈឺន ៖ បាទ!

កុសល ៖ ហេតុអីបានមិនទៅភូមិស្រុក?

ឈឺន ៖ ចុះវាខ្ជិលទៅៗដោយសារវានៅតែកូនក្មួយ ទៅមិនដឹងទៅសម្បីមអី ទៅនិយាយអីៗ

កុសល ៖ ចឹងពូមិនចឹងដឹងថា ពួកគាត់រស់យ៉ាងម៉េច កូនចៅអីម៉េចៗ មានចង់ដឹង?

ឈីន ៖ កូនក្មួយដឹងមាន មកពីឆ្នាំមុនម្តង មកពីរនាក់ ក្រៅពីនោះអត់ៗ បើបងខ្ញុំងាប់អស់រលីង ហើយគ្មានសល់ទេ ឪពុកស្លាប់តាំងពី៧៣ ម្តាយនៅ ដល់ខ្ញុំមកនេះរបូតប្រុច ម្តាយស្លាប់ទៀតៗ

កុសល ៖ ពេលជួបអ្នកមីងៗធ្វើអី ធ្វើការជាមួយគ្នា ទាហានដូចគ្នា ក្នុងកង?

ឈីន ៖ គ្រួសារខ្ញុំៗ

កុសល ៖ បាទ! គ្រួសារលោកពូៗ

ឈីន ៖ គេនៅផ្ទះដែរៗ

កុសល ៖ ឃើញគ្នាក៏ចាប់អារម្មណ៍ទៅ?

ឈីន ៖ បាទ!

កុសល ៖ កូនពូ៥នាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន នេះចៅ?

ឈីន ៖ ចៅអីកូនៗ

កុសល ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឈីន ៖ ស្រី២ ប្រុស៣ៗ នោះកូនប្រសារៗ

កុសល ៖ តើថាធ្វើម៉េចទៅឲ្យមានការផ្សះផ្សាជាតិ? ជីវិតរបស់លោកពូ ខ្ញុំជាក្មេងសារក្រោយស្តាប់ទៅហាក់ដូចជាភាពជូរចត់ ការតស៊ូនឹងវាពេញក្នុងខ្លួន ដូចពូថាចឹងខ្មែរវ៉ៃខ្មែរ វ៉ៃគ្រប់ជំនាន់ វ៉ៃតែខ្មែរគ្នាឯងៗ មុនដំបូងគេឲ្យ១៩ឆ្នាំ គេឲ្យពូទៅវ៉ៃ លន់ នល់ ក្រោយមកគេថាឲ្យវ៉ៃទ័ពយួន ប៉ុន្តែក្នុងនឹងក៏មានខ្មែរដែរ ជំនាន់សាធារណរដ្ឋៗ

ឈីន ៖ នោះឯងៗ

កសល ៖ វ៉ៃរហូត?

ឈីន ៖ វ៉ៃរហូត វ៉ៃតែគ្នាឯងៗ

កុសល ៖ វ៉ៃតែគ្នាឯង ងាប់តែគ្នាឯងៗ ចឹងខ្ញុំសួរ ក្មេងជំនាន់ក្រោយខ្ញុំឆ្ងល់ថា ធ្វើម៉េចទៅឲ្យមានការផ្សះផ្សាជាតិ ពាក្យផ្សះផ្សា មានន័យថាឲ្យយើងរស់នៅបានសុខដុមរមនាជាប្រជាជនតែមួយ ជាពលរដ្ឋតែមួយ ជាមូលផ្តុំគ្នាក្នុងការកសាងប្រទេសជាតិៗ ព្រោះប្រទេសយើងមានការប្រេះស្រាំច្រើនចឹង ដោយសារសង្គ្រាមបែកបាក់គ្រួសារ ដូចលោកពូផ្ទាល់បែកបាក់គ្រួសារៗ យើងធ្វើម៉េចទៅឲ្យមានការផ្សះផ្សាជាតិ? ពូគិតមើល ឲ្យយោបល់ឲ្យខ្ញុំយល់ បង្រៀនឲ្យខ្ញុំដឹងខ្លះ ត្រូវធ្វើយ៉ាងម៉េច?

ឈីន ៖ ខ្ញុំថាមករឿងគំនិតដើម្បីឲ្យដឹងថា ជាតិផ្សះផ្សាជាតិ ឲ្យស្រុកយើងក្នុងសង្គមយើងបានសន្តិភាពយូរអង្វែង លុះត្រាតែឪពុកម្តាយចេះប្រៀនប្រដៅកូន ហើយកូនក៏មិនសូវឆ្លកទៅតាម

សង្គមភ្លើតភ្លើន ទៅតាមមានរបបសេរី មានអ្នកស្លូត មានអកចេះ មានអ្នកស្លូតៗ យើងឲ្យដឹងថាធាតុយើង ឧបមាថា បើខ្ញុំយល់ ដូចខ្ញុំជាកសិករ ធាតុពិត គឺស្រែ ភ្លឺ គោ ក្របី មិនគួរណា យើងជាកូនភ្លើតភ្លើនទៅតាមមិត្តភ័ក្តមិនសមគួរនឹងទស្សនៈបងប្អូន ស៊ីដឹក សក់ហាយឡាយ បង្ហោះម៉ូតូ ខោសំយ៉េស ហើយម៉ែឪថាមិនស្តាប់ៗ នេះសព្វថ្ងៃ ខ្ញុំមិនដឹងថាម៉េចទេ កូនៗសព្វថ្ងៃគឺច្បាស់ណាស់ៗ

កុសល : ចុះលោកពូយល់ថា ដូចអ្នកខ្លះគេថាចេះ ដោយសារថាប្រទេសយើងមានដូចរាល់ថ្ងៃលោកពូដែលឮតុលាការនៅភ្នំពេញ?

ឈើន : ហ្នឹងហើយៗ

កុសល : តុលាការកាត់ទោសពួកមេៗ ហើយគេថាដើម្បីឲ្យមានការផ្សះផ្សាជាតិលុះត្រាតែមានយុត្តិធម៌ មានតុលាការ ចឹងពួកបរទេសនឹងមករៀបចំឲ្យមានការកាត់ទោសអីចឹង នៅភ្នំពេញសព្វថ្ងៃៗ ហើយពូមានឮដំណឹងពីនឹង មានដឹងទេ?

ឈើន : ទេ! ឮៗតាមគេផ្សាយៗ

កុសល : អត់ដែលបានទៅៗនោះ?

ឈើន : អឺ! ទម្រាំទៅសៀមរាបនោះ៣-៤ខែមិនដែលឃើញៗ

កុសល : ទម្រាំដល់ភ្នំពេញ?

ឈើន : យី! មិនឆាយទេ តែអន្ទង់វែងនេះ តែរវល់មិនបានទៅដែរ ព្រោះតែដើរហើយ គឺចាយតែចាយហើយខ្លួនឯងអ្នករកលុយពិបាកវេទនានោះវាយ៉ាប់ៗ

កុសល : ចឹងពូមិនបានតាមដាន រឿងចាប់អារម្មណ៍អីតុលាការគេធ្វើនៅភ្នំពេញប៉ុននឹងទេ គ្រាន់តែដឹងឮតែប៉ុននឹង?

ឈើន : គ្រាន់ដងឮនោះៗ

កុសល : ពូយល់យ៉ាងម៉េចដែលចំពោះតុលាការនឹង អាចជួយផ្សះផ្សាបាន?

ឈើន : ដឹងបានមិនបាន លើគេផ្សះផ្សាបង្រួបង្រួមម៉េចៗ កាត់ម៉េចអីម៉េចៗ

កុសល : ពូយល់ថាតុលាការនឹងធ្វើឲ្យយើង ចង់និយាយថាធ្វើនឹងតម្រូវតាមអ្នកដែលទទួលរងបាត់បង់ឪពុកម្តាយជនានរបប៣ឆ្នាំៗ តើពូយល់ថា តើមានភាពយុត្តិធម៌ទាំងសងខាងទេ ផ្តល់យុត្តិធម៌ នាំឲ្យមានការផ្សះផ្សាទេ ឬពូទាមទារឲ្យមានយុត្តិធម៌មិនចឹង ហើយបានគេបង្កើតតុលាការនឹងមក មានបរទេសមានខ្មែរៗ ឥឡូវគេចាប់ផ្តើមកាត់ទោសតែអ្នក៤នាក់ ខាងលើដូចជា ខៀវ សំផន, អៀង ធីរិទ្ធ, នួន ជា, អៀង សារី ៤នាក់នឹងករណីទី២ៗ តើ

លោកពូយល់ថា វាធ្វើឲ្យយើងបែកបាក់គ្នា ឬក៏ធ្វើឲ្យយើងផ្សះផ្សា ការកាត់ទោសបែបនឹង បើតាមពូយល់?

ឈឹន : អត់ទេ ខ្ញុំមិនសូវយល់ចេះទៅ នឹកឃើញថា វាមិនជាអីប៉ុន្មានទេ ទោះបីជាគេកាត់ក៏ម្យ៉ាង ដើម្បីយុត្តិធម៌ដែរ ពីព្រោះក្នុងសង្គមដែលយើងឆ្លងកាត់ទៅ ឧបមាថាយើងមានកំហុសទៅហើយ បើថាគេមិនកាត់ទោស គេមិនអីទៅធ្វើតាមក្បួនតាមខ្នាត គេចាប់បានដាក់ម៉ោកៗ ផាប់ទៅ ឥតប្រយោជន៍ ។

កុសល : ហេតុអីបានលោកពូថា ជំនាន់នឹងមានកំហុស របបពន្ធាំមានកំហុស ក្រែងអ្នកនឹងធ្វើដើម្បីជាតិដែរ?

ឈឹន : ធ្វើដើម្បីជាតិ ។

កុសល : ហេតុអីបានលោកពូយល់ថាមានកំហុសៗកន្លែងណា?

ឈឹន : អឺ! ដូចគេតែងផ្សាយកាលនឹងអស់ប៉ុន្មានលានៗ ខ្ញុំនឹកឃើញថាអានឹងជាកំហុសមួយ ប៉ុន បើគេអ្នកតស៊ូ គេថាជាតិដែរ ។ ប៉ុនភាគីម្ខាងគេចោទយើងថាយើងប្រល័យ អានោះដើម្បី យុត្តិធម៌នឹង ត្រូវវែកញែកអានោះ ។

កុសល : ត្រូវតែវែកញែកឲ្យច្បាស់?

ឈឹន : ចុះរបស់គេ ថាគេខំរបស់គេ ថាគេសំណោផលរបស់គេដែល ឯងនោះភាគីឯងនោះមកថា ភាគីខាងនេះមិនមានផលទេ គឺធ្វើបំផ្លាញថាចឹង ។

កុសល : ចឹងលោកពូយល់ថា អានឹងជាការបំភ្លឺទៅវិញទៅមក ជាការមួយសំខាន់ឲ្យដឹងរឿងទាំងសង ខាង?

ឈឹន : បាទ!

កុសល : ចឹងលោកពូយល់ថា តើអារឿងនឹងគួរតែបំភ្លឺទៅវិញទៅមកដែរទេ?

ឈឹន : បំភ្លឺ អាចដឹងកំហុសរៀងខ្លួន បើតាមខ្ញុំស្មានទេ ។

កុសល : ដូចថាអ្នកដែលទទួលរង មិនយល់ពីអ្នកដែលគេតស៊ូ?

ឈឹន : បាទ!

កុសល : ឬលោកពូថា លោកពូបានចូលបម្រើប្រទេសជាតិ នឹកស្មានថាធ្វើឲ្យប្រទេសជាតិនឹងទៅ មុខ ការពារព្រំដែន?

ឈឹន : បាទ! ចឹងឯង ។

កុសល : ហើយមិនដឹងទេ ថាខាងក្រោយនេះគេធ្វើអីខ្លះ?

ឈឹន : បាទ!

កុសល ៈ ចឹងវាខុសៗកន្លែងនឹង?

ឈឺន ៈ បាទ!

កុសល ៈ ចឹងលោកពូមានអារម្មណ៍ម៉េចដែរ ចំពោះអ្នកដែលគេថា ពួកខ្មែរក្រហមសុទ្ធតែអាក្រក់ទាំងអស់ អ្នកដែលពាក់ព័ន្ធនឹងរបបនឹងសុទ្ធតែអាក្រក់ មានកំហុស?

ឈឺន ៈ ខ្ញុំអត់ នឹកឃើញស្មានដល់នេះទេ ពីព្រោះខ្ញុំថា បើនិយាយពីខ្មែរក្រហមភាគច្រើនទាំងអស់ អ្នកខាងក្នុងពីមុនក៏ខ្មែរក្រហមដែល ពីដើមមិនថាចឹង។ ទើបប្រលែងនឹងថ្ងៃដែលយួនចេញមកទេ វានៅក្រោមការគ្រប់គ្រងរបស់ពីលើដូចតែគ្នាដែរនោះ។ ចុះហើយគួរតែយល់ គួរតែដឹង ដល់អាក្រោយនេះទេ ដែលបន្ទាប់គ្នាឯងលេងសំនំ រឿងដែលគេជ្រុះជ្រៀជាតិ ហើយយើងទៅបត់វាធ្វើអី គេបង្រួបបង្រួមគ្នាអស់ទៅហើយ អាខ្លះណាសម្លាប់អ្នកណា បាញ់អ្នកណាឡើងគេមិនយកទោសយកពៃរ៍អស់ទៅហើយ ឯងណាមកខំនិយាយលេង មិនថាចុះ។ អានោះសម្រាប់អ្នកមិនដឹកមិនហូបអង់អានឹងជាធម្មតាទេ ប៉ះអាអ្នកដឹកភ្នែករៀងក្រហមដែរ អានោះមុតដែរ ប្រហែលដាក់តែគ្នាឯង ផាប់តែគ្នាឯងនឹងទៀត។

កុសល ៈ ចឹងលោកពូឯកភាព ថាដូចថាពួកខាងក្នុងជាពិសេសមិនសូវយល់ពីការតស៊ូរបស់ដូចជនានពួកពូអីគេមិនយល់ តើពូមានអារម្មណ៍បែបនឹងទេ ពេលខ្លះ?

ឈឺន ៈ អត់ទេ។

កុសល ៈ ហើយគេមិនយល់ថាយើងតស៊ូយ៉ាងម៉េច លំបាកម៉េច?

ឈឺន ៈ ព្រោះថាមិនដឹង ព្រោះគេមិនដឹងបាន។

កុសល ៈ ត្រូវពន្យល់?

ឈឺន ៈ នោះហើយ។

កុសល ៈ ហេតុអីបានត្រូវមានការអត់ឱនទោសគ្នាទៅវិញទៅមក?

ឈឺន ៈ អត់ឱនទោស ដើម្បីហៅថាយើងចេះសន្ដោះប្រណីមិត្តភ័ក្តគ្នាឯង អ្នកមានកំហុស និងអ្នកអត់កំហុស ក៏យើងត្រូវតែលើកលែងគ្នាថា អ្វីគួរយើងអនុគ្រោះកំហុសពាក្យអីនិយាយធ្ងន់ស្រាល។ វាទៅលក្ខណៈមួយយើងជ្រុះជ្រៀ ហើយបង្រួបបង្រួមចិត្តគំនិត កាត់បន្ថយហៅថាអំពើហិង្សា ឲ្យមានជំហរសាមគ្គីគ្នាវិញ ហៅថាការលុបលាងកំហុសតិចតួច។ តែខុសយើងត្រូវនិយាយគ្នា ឯងធ្វើម៉េចខុសអី ឯងត្រូវអី។ បើថា យើងមិនស្វែងយល់ពីរឿងបង្រួបបង្រួម គំនិតចិត្ត និងជ្រុះជ្រៀគ្នាហៅថាខ្លាំងលិច ខ្លាំងកើត ល្បៀងអីតិចក៏នៅតែមានសតិអារម្មណ៍ ប្រឆាំង។

កុសល ៈ នៅកំហឹង?

ឈីន ៖ នៅតែប្រហែល គ្រាន់មាន់ដេរបញ្ញាសំចេះ ក៏ចាប់អារម្មណ៍គេប្រុងស្ដីឯងប្រឆាំងឯង នេះទស្សនៈមួយវាចេះ ។

កុសល ៖ ចុះចំពោះកំហុស និងការទទួលខុសត្រូវក្នុងរយៈពេល៣ឆ្នាំនឹង អ្នកណាគេគួរទទួលខុសត្រូវ ។ ឧបមាថាដូចការកាត់ទោស ថាតើថ្នាក់ណាទៅគួរតែយកមកកាត់ទោស?

ឈីន ៖ មិនដឹងថ្នាក់ណា ខ្ញុំថាអ្នកណាខ្ពស់ជាងគេ អ្នកនោះហើយ ។

កុសល ៖ ឥឡូវនឹង គេចាប់ផ្ដើមធ្វើចឹងហើយ គេចាប់ផ្ដើមយកអ្នកណាគេខ្ពស់ជាងគេ គេយកមកកាត់ទោស ដើម្បីស្វែងរកការពិតផង យុត្តិធម៌?

ឈីន ៖ អ្នកក្រោមគ្នាឧបមាថាយើងនិយាយថាដៃដល់ ប៉ុនមិនមានធ្វើខ្លួនឯង បទបញ្ជាទេ មានចឹងបានទៅ បើមិនមានបទបញ្ជាមិនប្រើទេ អ្នកណាគេទៅ ហើយទៅប្រើធ្វើអី បើប្រើធ្វើការងាររៀងយ៉ាប់ហើយ ស្អែកទៅហើយ ។

កុសល ៖ ចឹងអ្នកដែលនៅក្រោមទទួលបញ្ជាពីគេនឹង មិនគួរណាគាត់ទៅដាក់ទទួលកំហុសទេ កំហុសអ្នកដែលបញ្ជាពីលើមក?

ឈីន ៖ បាទ!

កុសល ៖ ចឹងលោកពូសន្មតថា គាំទ្រកុំឲ្យមានការកាត់ទោសតទៅទៀត លើសពី០០២លើសពី៤នាក់នឹង លើសពីមេហ្នឹង ដូចថាយើងបញ្ចប់ទៅ?

ឈីន ៖ មែន! ច្បាស់ណាស់ ។

កុសល ៖ តើពូឯកភាពថាវាគួរតែបញ្ចប់?

ឈីន ៖ គួរតែបញ្ចប់ទៅ ព្រោះអ្នក្រោមបញ្ជារបស់គេដែរ គ្មានអ្នកណាចង់ធ្វើទេ ។

កុសល ៖ ចុះចំពោះឌុច លោកពូយល់ ដែលពូថាឌុចៗ?

ឈីន ៖ ខ្ញុំមិនដែលដឹងទេ ឮតែឈ្មោះ ឮតែអីទេ ព្រោះខ្ញុំនៅណានោះ ។

កុសល ៖ គាត់ចាត់ជាថ្នាក់លើដែរ ហេតុអីបានគេដាក់គាត់គួរតែទទួលខុសត្រូវ? លោកពូយល់ថាគាត់នឹងគាត់គួរតែទទួលខុសត្រូវនូវអ្វីដែលគាតបានធ្វើ គាត់កាន់នៅគុកទួលស្លែងនៅភ្នំពេញ អ្នកខ្លះថាគាត់នៅក្រោមគេដែរ?

ឈីន ៖ គាត់ក្រោមៗប្រៀបដូចទទួលខុសត្រូវ បើនិយាយទៅដូចជាពិសេសមួយរបស់ថ្នាក់លើ និយាយទៅថាអគ្គរក្សពិសេស ។

កុសល ៖ កាន់គុកទាំងមូល វាធំដែរ?

ឈីន ៖ កាន់គុកទាំងមូល ។

កុសល ៖ ក្រោមតា សុន សេន?

ឈីន ៖ បាទ!

កុសល ៖ លោកពូ គិតថាការកាត់ទោសឲ្យគាត់ជាប់គុកនឹងយុត្តិធម៌ទេ ៣៥ឆ្នាំ?

ឈីន ៖ គ្មានអីតាមតែច្បាប់ទៅ ច្បាប់វិនិច្ឆ័យយ៉ាងម៉េច ទៅកម្រិតណា ប៉ុននោះឯងវាគេសមូហភាពក្នុងតុលាការ គេឲ្យឯងជាប់ខ្លីពេលវាមិនទំនង ព្រោះឯងមេឡើងកញ្ចាស់ផងដែរ ហើយនយោបាយឆ្អែតពេញប្រទេសអស់ទៅហើយ ។ ក៏ដូចបងប្អូនផ្សេងៗ ថាគ្នាគ្រាន់តែមារ មីង មេជ្រូក អាស្តីគ្រាន់មេគ្នាគេប្រើក្រឡឹកវិលពេញខួរក្បាលនោះគ្មានដឹងរឿងអីទេ ដាក់គ្នាបានមកវេទនាកម្មនោះឯង ។

កុសល ៖ ចឹងលោកពូគិតទៅវិញ គិតត្រឡប់ទៅតាំងពីអាយុ១៩ឆ្នាំចេញពីភូមិស្រុកមក ឲ្យទៅធ្វើទាហានការពារជាតិ តំបន់នេះចូលក្នុងរបបនឹង តើពូដែលជឿជាក់ថា ជឿជាកលើគោលនយោបាយជំនាន់នឹងដែរទេ ថាធ្វើឲ្យប្រទេសជាតិរឹងមាំ ។ ពេលនឹង ពូជឿជាក់ថាគេធ្វើរបបនឹងធ្វើឲ្យប្រទេសជាតិរឹងមាំដែរទេ ពេលនឹង?

ឈីន ៖ ពីជំនាន់សម័យកសាង?

កុសល ៖ បាទ!

ឈីន ៖ ខ្ញុំ ក៏មិនទាន់ហ៊ានថាដែរ ។ ម៉េចបានមិនទាន់ហ៊ានថា ពីព្រោះខ្ញុំអត់សូវបានដឹងច្បាស់ពីរឿងនយោបាយខាងក្រោយច្រើនទេ ខ្ញុំនៅទាហាន ដឹងពូមកតែរឿងការងារទាហាន ។

កុសល ៖ គេដាក់បញ្ជាឲ្យធ្វើនឹង?

ឈីន ៖ បាទ!

កុសល ៖ ពូដែលមានមិនគោរពបញ្ជាគេ ដែលគេដាក់បញ្ជាមកពូមិនគោរព មានដែលជំទាស់ ហ៊ានជំទាស់?

ឈីន ៖ មិនហ៊ានទេ ។ គ្មានរឿងអីជំទាស់ផងកាលនោះ សម័យកសាង ព្រោះទាហានអត់មានធ្វើស្រែផង គ្រាន់គេឲ្យបិទការដ្ឋានតិចៗរួមជាមួយប្រជាជនទៀតនោះ គ្មានអីធំដុំហូបបាយហូបអីនឹង ។

កុសល ៖ ហើយយើងមានចាប់បានជនក្បត់ដូចពួកសេ.អ៊ី.អា កា.ហ្សេ.បេ ក្នុងក្រុម មានចាប់បានទេជំនាន់នោះ មានពួកដូចធ្វើវិទ្ធស្សនា ចាប់បាន?

ឈីន ៖ អត់ៗ ។

កុសល ៖ ដែលមានពួកថៃ ពួកអី ទាហានសេរី តាអ៊ិន តាំ អីមានទេ?

ឈីន ៖ អតទេ ។

កុសល ៖ ចុះពូគិតទៅវិញ ពូយល់ថា ពូជាជនរងគ្រោះ ឬក៏ជាអ្នកបដិវត្តន៍ល្អមួយរូបក្នុងសម័យនោះ?

ឈើន ៖ ហេ!ខ្ញុំមិនថាទេ ខ្លួនខ្ញុំនោះ ខ្ញុំថាខ្ញុំធ្វើមួយស្រួល ម៉ាទំនងរបស់ខ្ញុំ បើធ្វើមិនសំនុំខ្ញុំថាខ្ញុំមិនបាន រស់នៅដល់ប៉ុននេះ ។

កុសល ៖ មានន័យថាម៉េច ថាពូធ្វើល្អ តាម?

ឈើន ៖ ធ្វើល្អឲ្យបានសមរម្យទៅតាមអ្នកដទៃ ។

កុសល ៖ អ្នកដទៃជំនាន់ហ្នឹង តាមអង្គការជំនាន់ហ្នឹង?

ឈើន ៖ បាទ! ហៅថាវិលៗ បើវិលមិនទាន់ យើងវិលតែសម្តី ការងារមិនធ្វើឲ្យគេអស់ចិត្តក៏ ។

កុសល ៖ វិលនឹងយ៉ាងម៉េច យើងធ្វើទៅតាមសកម្មភាពបត់បែនទៅតាមគេ?

ឈើន ៖ បត់បែនគេប្រើយើងឲ្យធ្វើអី យើងប្រាប់ថាយើងទទួលខុសត្រូវ៤-៥នាក់ ១០នាក់យើងត្រូវរៀបចំចចាត់ចែង អាណាត្រូវទៅធ្វើអីៗ ធ្វើដើម្បីឲ្យស្អាត កុំឲ្យគេថាយើងស្អីៗណាណា ។

កុសល ៖ ថាយើងប្រតិកិរិយា ថាខុស?

ឈើន ៖ អឺ! ថាយើងខុសឆ្គង ថាឯងវា ។

កុសល ៖ ចឹងពេលនឹងពូបារម្ភៗ ថាធ្វើខុស បារម្ភមែន ។

ឈើន ៖ ហ៊េ! តែធ្វើខុស គេកសាងតែ៣-៤-៥-៦ដងមិនបាន ជាប់សន្តិសុខហើយ គ្មានរឿងអីណា ។

កុសល ៖ ចុះនៅក្នុងនឹង ទាហានក៏មានសន្តិសុខដែរ?

ឈើន ៖ គេបញ្ជូនមកពីកន្លែងស្រុក កន្លែងខេត្តនេះ ។

កុសល ៖ ទៅធ្វើខុសអី ចូលមកខេត្ត?

ឈើន ៖ នោះហើយ ។

កុសល ៖ ក្នុងក្រុមរបស់ពូមានគេបញ្ជូនមកដែរ?

ឈើន ៖ មានខ្លះណា អានឹងខុសធ្ងន់ៗណាស់បាន ។

កុសល ៖ ខុសអីខ្លះបានគេបញ្ជូនមក?

ឈើន ៖ មនគោរពគេ ព្រហើន លិចកើត ដើងត្បូង ធ្វើអីខ្ជិលអានោះកាលនោះ គេត្រូវសំរិតសំរាំងទៅហើយ តែធ្វើអីមិនសំនុំ មិនជាខុសដល់ទៅវ៉ៃចោលគេ តាមពិតសម្តីយើង ។

កុសល ៖ គេមកតម្រង់ទិស?

ឈឺន ៖ បាទ! នោះហើយ គេអប់រំតែម្តង២ដង ថ្ងៃក្រោយនៅតែដឹរដាក់គ្នាទៀត នៅនេះសន្តិសុខហើយ ។ បើថាទាហានសព្វថ្ងៃ ទាត់សាញកូថខោបានចាប់ដាក់ ។

កុសល ៖ ចុះនៅក្នុងជួរនឹង ដូចពូដាក់បញ្ជានឹង អ្នកណាដាក់បញ្ជាមក ពីខាងកងទ័ព អ្នកណាខាងលើគេដាក់បញ្ជាឲ្យក្រុមពូទៅធ្វើនេះធ្វើនោះ ដូចពូថាមិញ?

ឈឺន ៖ តាមរយៈពីតាម៉ុក តា វិន បើតា គាត់បញ្ជាតែរឿងផែនការធំៗ គ្រាន់បច្ចេកទេសរៀនសូត្រអីខាងធ្វើស្រែ ឬខាងដើរការពារ ត្រូវដឹកលានដ្ឋាន ត្រូវដឹកអី គាត់ហៅអាមេបន្ទាប់ទៅបង្រៀន ទៅមានផែនទីអី ។

កុសល ៖ ជំនាន់នេះតាម៉ុកមកដល់នេះហើយ ៧៥ ៧៦?

ឈឺន ៖ អានោះហើយណា ៧៥ ៧៦ ៧៧ ៧៨ ៧៩ ។

កុសល ៖ តាម៉ុកគាត់បញ្ជាដល់ថ្នាក់ទូទាំងប្រទេស?

ឈឺន ៖ មួយចំហៀងទៅហើយ ដល់ទៅមេក្រោមៗមកក៏បង្រៀនទៅពន្យល់ចែកផែនការគ្នាទៅណាហើយខ្ញុំធ្វើតាមគេ ។

កុសល ៖ ចុះខ្ញុំមានសំនួរដាក់លាក់មួយចំនួនគឺថា ត្រឡប់ទៅភាពផ្សះផ្សាវិញ ដើម្បីផ្សះផ្សាវិញលោកពូថា លោកពូចង់ឲ្យមានការអនុគ្រោះគ្នាទៅវិញទៅមក?

ឈឺន ៖ បាទ!

កុសល ៖ អានឹងជាសំខាន់មួយ ចុះរឿងខ្ញុំត្រឡប់មកវិញរឿងតុលាការគេ ហេតុអីបានតុលាការសព្វថៃព្រោះគេកំពុងតែធ្វើទៅហើយ រាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិគេធ្វើទៅហើយ ។ ហើយជាពិសេសខ្ញុំចង់ដឹងទស្សនៈរបស់ពូផ្ទាល់ ថាតើវាមានសារៈសំខាន់បែបណាខ្លះ? ដូចថាលោកពូមិនសូវបានតាមដានផង សំនួរសួរថា តើលោកពូចង់ ដើម្បីការផ្សះផ្សាចំពោះអតីតរបស់ខ្លួន តើលោកពូចង់ឲ្យមេដឹកនាំក្នុងរបបពន្លាំនឹង ទទួលទោសកម្រិតធ្ងន់បំផុត ពូឯកភាព ឬម៉េច? ពី១ដល់៥ ១មិនឯកភាព ៥ឯកភាពខ្លាំងបំផុត ។ ដាក់ទោសឲ្យធ្ងន់បំផុត មេដឹកនាំមេៗ ។ តើលោកពូឯកភាព ឬមិនឯកភាព សំនួរនឹង ដើម្បីការផ្សះផ្សា និងយុត្តិធម៌?

ឈឺន ៖ ឲ្យធ្ងន់ខ្លាំង ដល់ទៅស្លាប់ដូចមិនទំនង គាត់ចាស់ប៉ុននេះទៅហើយ ។

កុសល ៖ គាត់ចាស់ទៅហើយ?

ឈឺន ៖ បាទ! វាគួរតែបន្ធូរខ្លះទៅតែតិចទៅអស់ព្រះជន្មនទៅបាត់ទៅហើយ គាត់ព្រួយចិត្តនោះងាប់បាត់ហើយមិនថាម៉េចទេ មិនផ្តន្ទាគាត់អីទេ មនុស្សសូម្បីតែខ្ញុំប៉ុននេះក៏ដោយ តែអន់ចិត្តហើយ វាមិនត្រឹមតែអន់ចិត្តឹងទេ អាអន់ចិត្តខ្មាស់គេនេះវាធំណាស់ អ្នកនយោបាយ

មិនបាច់ទៅដូចគេថាទៅដាក់គុកៗ មិនបាច់ទៅចាំយកឈ្មោះទៅដាក់ទេ គេគ្រាន់តែខាងនោះយើងដើរ សឹងតែគេអត់ដង្ហើមស្លាប់ អត់ស្លាប់បាត់ទៅហើយ ។

កុសល : ចឹងគួរតែបន្ថយគាត់ចាស់ហើយ?

ឈើន : បាទ!

កុសល : ចុះចំពោះកម្មាភិបាលថ្នាក់តំបន់ និងថ្នាក់លេខា ដូចថាថ្នាក់ភូមិភាគ ជំនាន់នឹង មេភូមិភាគអីគួរតែយកមកកាត់ទោសដែរទេ?

ឈើន : ខ្ញុំថាដូចមិនទំនងទេ អានឹងតាមចិត្តខ្ញុំទេ ។

កុសល : បាទ! ខ្ញុំចង់ដឹងពាក់យោបល់របស់ពូហើយ ។ ចុះអ្នកធ្វើខាងក្រោមៗ ដូចជាអកជនដៃដល់ប៉ុន្តែគេត្រូវបញ្ជាគេដែរ គួរតែយកមកកាត់ទោស ហើយម៉េច?

ឈើន : មិនបាច់ទេ បើតាមខ្ញុំសណ្ដោសប្រណីយោគយល់គ្នា កំហុសដោយសារអី ដោយសារតែគេបញ្ជាដែរ ។

កុសល : កំហុសវាខុសហើយ ប៉ុន្តែធ្វើដោយសារបញ្ជាគេដែរ?

ឈើន : បាទ! ឲ្យចេះតែយកមកយកៗ គ្នាជម្រើសវាច្រើន វាចេះតែតូចចិត អញនេះកើតមេនឹងគេដែរ អញភ័យ ចេះតែភ័យបន្តៗ យូរផ្អើល ចង់បែកបាក់សាមគ្គីទៀត នេះទស្សនៈខ្ញុំទេណា ។ វាមិនទៅប្រាលនឹងធ្វើសង្គ្រាមទេ ប៉ុន្តគ្នាវាខ្លាចសឹងតែដេកផ្ទះមិនបានផង ថាចុះអានេះគំនិតខ្ញុំទេណា ។

កុសល : ចុះដើម្បីការផ្សះផ្សា តើយើងគួរតែបំភ្លេចចោលអតីតកាល?

ឈើន : បំភ្លេចហើយយើង ចុះរៀនសូត្រដឹងហើយតើ គាត់នៅក្រោម ដែលថាមានឋានៈក្រោមក៏ចូលរៀនកើតជា អាអ្នកក្រោយក៏កើតជាមេខ្លះទៅហើយ ។ ចុះខ្លួនឯងដឹកនាំធ្វើ នោះមិនដឹង មេធ្វើសព្វថ្ងៃ មេនោះធ្វើដើម្បីអី ដើម្បីបន្ទំ ឬក៏ធ្វើទៅតាមគោលការណ៍រដ្ឋាភិបាលមិនថាចុះ ។ អាខ្លះដល់ចៅហ្វាយខេត្ត ចៅហ្វាយស្រុក សុទ្ធតែមេខ្មែរក្រហមដដែល ។

កុសល : ឥឡូវសុទ្ធតែផ្កាយ២ ផ្កាយ៣ ។

ឈើន : បាទ! ទៅថាយ៉ាងណា ទៅលរមើលតាលិញ រត់ទៅណារត់រួច គ្នានោះមិនយ៉ាប់ហើយ ។ មានអីទីតាំងៗពេញតែវាលនោះឯង ។

កសល : ពូដឹងច្រើន ។ ចឹងចំពោះដូចថាគេបង្កើតឲ្យមានតុលាការនៅភ្នំពេញ កាត់ទោសមេដឹកនាំខ្មែរក្រហមជំនាន់ហ្នឹង តើលោកពូសប្បាយចិត្តទេ ដែលគេធ្វើចឹង?

ឈើន : ទេ! គ្មានអី ។

កុសល : តិច ឬក៏ច្រើន?

ឈឺន ៖ សប្បាយចិត្តបានគ្រាន់បើ ត្រង់ថា មិនភ័យក្រែងគ្នាអ្នកមានកំហុស ធ្វើអីត្រង់ណាៗ ក៏មិនជះទៅតាមកំហឹងបុគ្គលបាន តែហ៊ានទៅសងសឹកទៅអីតាមកំហឹងរបស់ឯង ចាប់យកមកបាញ់ ចាប់យកទៅដាក់គុកទទឹងទទេង អត់កើតៗ ខ្ញុំនឹកឃើញទេណាៗ ទៅដល់ឯងធ្វើច្បាប់មាន ហើយគ្នាប្រព្រឹត្តកំហុសកម្រិតណា អ្នករងគ្រោះកម្រិតណា ហើយឯងនេះអ្នកចាប់ចងគេទៅនោះ ឯងវាត្រូវរបស់ឯងកម្រិតណា ដល់ចឹងមានយុត្តិធម៌រៀងខ្លួនទៅ គ្នាក៏មានសង្ឃឹមក្នុងការរស់នៅដែរៗ

កុសល ៖ ថ្នាក់ក្រោមមានសង្ឃឹមក្នុងការរស់នៅ?

ឈឺន ៖ បាទ! មានសង្ឃឹម បើថាអត់ស៊ីសុះៗ លុយដូចសព្វថ្ងៃ ស្រាសំបូរដូចសព្វថ្ងៃ ជុលគ្នា ក៏បាញ់គ្នាងាប់អស់ចឹងហើយៗ គ្មានស្តីអីមុតប្រហែលអាខ្មោចស្រា ថ្នាំញៀននេះ ដាក់ឲ្យកូនក្មេងៗ

កុសល ៖ ចឹងតុលាការនេះជារឿងមួយល្អដែរ នាំឲ្យមានអ្នកក្រោមនឹងឈប់មានការភិតភ័យ?

ឈឺន ៖ បាទ! ល្អតើៗ អត់មានការភិតភ័យ អត់ភ័យព្រួយថាយ៉ាងណាទេៗ

កុសល ៖ ចឹងតុលាការនឹងធ្វើឲ្យមានការផ្សះផ្សាដល់កម្រិតណាដែរ ការផ្សះផ្សាជាតិកម្រិតណាពី១ដល់៥ ១តិច ៥ច្រើន?

ឈឺន ៖ បានក្រែលដែរ ខ្ញុំថាឲ្យប្រជាជនយកចិត្តទុកដាក់ គឺក្រែល ៥០-៦០-៧០ភាគរយដែរៗ

កុសល ៖ ប្រហែលជា៤?

ឈឺន ៖ បាទ! បើមានតុលាការហើយ បងប្អូនមានសង្ឃឹម ហើយអ្នកប្រព្រឹត្តតែឃើញតុលាការកន្លែងសន្តិសុខជីងតែខ្លាចហើយ មិនសូវហ៊ានទេៗ

កុសល ៖ ពូថាមិនសូវបានតាមដានពីតុលាការនឹងប៉ុន្មាននេ ហេតុអី? ពូមិនចាប់អារម្មណ៍ ឬក៏ថាយល់ថាវាមិនសូវសំខាន់?

ឈឺន ៖ ហ៎! នឹកឃើញថាសំខាន់ដែរ ក៏ប៉ុន្តែខ្ញុំមិនសូវដែលបានរៀនបានអី ធ្វើមេណាណ ស្តាប់វិទ្យុតាមដានចេះចុះៗ តែគ្រដេកលក់ ចេះស្តាប់លេងទៅ ម៉ោង១០ ១១មិនទាន់ដេកជួនណា ឲ្យតែព័ត៌មានណាដាក់ៗ

កុសល ៖ ខ្ញុំសុំសួរបន្តទៀត ពូឆ្លើយមកពេញនេះជួយបំភ្លឺបានច្រើនៗ លោកពូយល់ថា បើសិនជាអ្នកដែលត្រូវបានយកមកសម្លាប់នៅក្នុងរបបនេះជាសត្រូវរបស់រដ្ឋ ឬក៏ជាការប្រឆាំងនឹងអង្គការ ដូចជាភ្នាក់ងារសំងាត់ កា.ហ្សេ.បេ, នាយទុនវណ្ណៈ តើការសម្លាប់ពួកនឹងខុសដែរទេ?

ឈឺន ៖ ការសម្លាប់ពីដំនាន់នោះ?

កុសល ៖ បាទ! បើដាសត្រូវ ។

ឈីន ៖ ខ្ញុំពិបាកថាណាស់ត្រង់នេះ ថាគេធ្វើត្រូវអ្នករងគ្រោះថាគ្នាខុសទាំងស្រុង ប៉ុនបើរឿងខុសនោះ មិនជាខុសធំដុំប៉ុន្មានទេ បើតាមមើលទៅ ។ ដល់ឲ្យខ្ញុំវិនិច្ឆ័យរឿងត្រង់នេះ ខ្ញុំពិបាកនិយាយ ។

កុសល ៖ ពិបាក?

ឈីន ៖ បាទ! ពិបាក ។

កុសល ៖ ពិបាក! ប៉ុន្តែបើឲ្យខុសក៏មិនខុសប៉ុន្មានៗ សត្រូវ?

ឈីន ៖ មិនខុសប៉ុន្មាន គ្រាន់តែប្រើធ្វើការទៅ គ្នាខ្ជិលគ្នាអី តាមការល្មើយ តាមការអីមិនថាចឹងចោទប្រកាន់ថាចេះចះទៅ ។

កុសល ៖ ចុះបើសិនជាឧបមាថា អ្នកដែលដល់ខាងក្រោម ឧបថា គាត់ទទួលបញ្ជាឲ្យធ្វើទារុណកម្ម ប៉ុន្តែបើគាត់មិនធ្វើទេ គេប្រាប់ថាបើមិនធ្វើទេគ្រួសារគាត់ត្រូវគ្រោះថ្នាក់?

ឈីន ៖ មិនធ្វើមានអី ឯងត្រូវរងទៀតហើយ គេចោទប្រកាន់ឯងទៀត ។

កុសល ៖ ចឹងការធ្វើនឹងអត់ជាខុសទេ មិនចឹងដោយសារគ្រួសារគាត់នេះ?

ឈីន ៖ គេបញ្ជាមក ឯងមិនធ្វើគេបន្ទោសឯងទៀត ស៊ីគ្រលុំលិចកើតជើងត្បូងវាទៅចុះទៅវិញ អូ! ចឹងមិនខុសចាស់ៗគាត់ថា ទូកខ្ចី ។

កុសល ៖ បើមិនធ្វើទេ គេថាអ្នកឯងមិនមែនជាបដិវត្តន៍ល្អ មិនដើរតាមបដិវត្តន៍ ពូឯកភាពនឹងចម្លើយនឹងទេ បើមិនធ្វើទេវាខុសនឹងគោលការណ៍បដិវត្តន៍?

ឈីន ៖ ខ្ញុំថាដូច ។

កុសល ៖ តែគេធ្វើតាមគោលការណ៍បដិវត្តន៍?

ឈីន ៖ គេធ្វើទៅតាមគោលការណ៍គេ ប៉ុនធ្វើទៅវាអត់ត្រូវទាំងស្រុង ចុះគ្នាអត់មានកំហុសអីធ្ងន់ធ្ងរផង អានោះខ្ញុំនឹកឃើញថា បើធ្វើទៅវាមិនជាត្រឹមត្រូវទាំងអស់ គ្មានអនុគ្រោះទៅតាមកំហុសដែលគ្នាប្រព្រឹត្ត ។

កុសល ៖ ចុះចំពោះអ្នកដែលថា ខ្ញុំបានដឹងពីរឿងបញ្ហាកើតការកាប់សម្លាប់ជំនាន់នឹង ប៉ុន្តែខ្ញុំមិនបានប្រព្រឹត្តទេ តើពូឯកភាពថាតើគាត់ទទួលត្រូវ ឬខុស? ថាមនុស្សម្នាក់មិនអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានដឹង តែមិនបានប្រព្រឹត្តទេ ត្រូវឬខុស ពី១ដល់៥?

ឈីន ៖ ខ្ញុំថាមិនគួរ បើយើងគ្រាន់តែដឹង យើងអត់អនុវត្តធ្វើ ។ អត់បានទទួលធ្វើ ។

កុសល ៖ ចុះបើគាត់ធ្វើតាមបញ្ជារបស់គេសុទ្ធសាធ អានឹងគួរគាត់ទទួលកំហុសទេ?

ឈីន ៖ អត់ ។

កុសល ៖ ពូឆ្លើយម្តងហើយមែនទេ មនុស្សម្នាក់មិនអាចទទួលខុសត្រូវចំពោះអ្វីដែលខ្លួនគាត់ធ្វើតាមបញ្ជាគេ?

ឈីន ៖ បាទ!

កុសល ៖ ដូចថាអ្វីដែលពួកឌុច គាត់បានធ្វើជាការសមហេតុផល ព្រោះអង្គការឲ្យគាត់ធ្វើចឹង? ខ្ញុំសួរមកទាក់ទងនឹងរដ្ឋាភិបាលឥឡូវ ទាក់ទងនឹងសង្គម ពូជឿទៅលើព្រះពុទ្ធសាសនា? ថាតើពូជឿលើដូចថា ជំនាន់នឹងគេអត់ឲ្យមានទេ ព្រះពុទ្ធសាសនា?

ឈីន ៖ ជំនាន់នោះ?

កុសល ៖ បាទ! ជំនាន់៣ឆ្នាំ គេលុបបំបាត់ចោលមិនចឹង?

ឈីន ៖ អឺ!

កុសល ៖ តើពូឥឡូវជឿលើព្រះពុទ្ធសាសនាច្រើនជាងមុន ឬយ៉ាងណា?

ឈីន ៖ នៅធម្មតា ។

កុសល ៖ មិនច្រើនមិនតិច នៅប៉ុននឹង?

ឈីន ៖ បាទ! តែប៉ុននឹង ។

កុសល ៖ ជឿលើកម្មផលទេ?

ឈីន ៖ ជឿដែរតើ ម៉េចថាមិនជឿ ។

កុសល ៖ តិច ឬច្រើន?

ឈីន ៖ អនុវត្តទៅតាមគោលការណ៍ជាក់ស្តែង រឿងព្រះពុទ្ធសាសនាខ្ញុំជឿ បើបុគ្គលធ្វើឲ្យជឿៗ ធ្វើមិនឲ្យគោរព ខ្ញុំអត់គោរព ។

កុសល ៖ ចុះចំពោះស្រុកភូមិ សព្វថ្ងៃនេះ ពូយល់ថាមានការសាមគ្គីភាពបែបណាដែរ ពូទុកចិត្តអ្នកជុំវិញ ជិតខាងដែរទេ? មានទំនុកចិត្តគ្នាទៅវិញទៅមក អ្នកជិតខាង? សាមគ្គីភាពគ្នាទៅវិញទៅមក?

ឈីន ៖ បើនិយាយសាមគ្គីបានល្អច្រើនហើយ ។

កុសល ៖ ខ្ញុំឮថា អ្នកថ្មីចូលមកនឹងមានបញ្ហាច្រើន មែនទេពូ? ថាមានអ្នកចំណូលថ្មីមកពីខាងក្រៅច្រើនបង្កបញ្ហា តើមែន ឬយ៉ាងម៉េច?

ឈីន ៖ អ្នកចូលថ្មី បើនិយាយពីក្នុងភូមិនេះមិនសូវទេ ចូលក៏ចូលសុទ្ធតែអ្នកស្រែចំការដែរ អត់សូវមានអ្នករសាត់មកពីឆ្ងាយៗ ហៅថាអស់ពីនេះទុំនោះ អស់ពីនោះទុំនេះ កន្លងមកមានដែលក្នុងឃុំនេះវាមានៗ ខ្លះមកពីកំពត ខ្លះមកពីកំពង់ចាម ខ្លះមកពីណា នាំកូនប្រពន្ធមកយូរៗទៅ លេងអស់បានដីបាននេះលក់អស់ ដីនេះក៏ទៅ វាមានចេះឯង ។

កុសល ៖ ចឹងពូយល់ថាគោលនយោបាយស្រុកភូមិសព្វថ្ងៃនឹង គឺដើរទៅផ្លូវត្រូវ ឬមួយយ៉ាងណា សព្វថ្ងៃ ពូជឿទុកទំនុកចិត្តទៅលើស្រុក ភូមិ ដូចអាជ្ញាធរដើរត្រឹមត្រូវដែរទេ?

ឈីន ៖ ធ្វើទៅតាមគោលការណ៍ត្រូវរបស់គេហើយ ។

កុសល ៖ ចឹងទំនុកចិត្តអ្នកជិតខាងក៏ខ្ពស់ដែរនោះ ពី១ដល់៥?

ឈីន ៖ បាទ!

កុសល ៖ ៥ខ្ពស់ ១០០ភាគរយ?

ឈីន ៖ បាទ!

កុសល ៖ ទំនុកចិត្តលើភូមិស្រុកក៏ច្រើនដែរ?

ឈីន ៖ បាទ! ព្រោះចេញមកតាមគោលការណ៍ច្បាប់ តែដោយបុគ្គលច្បាប់ចេញមកចេះឯង អនុវត្តគេផ្សេង តែយូរៗគេដឹងបាត់ហើយ ។

កុសល ៖ ពូមានបារម្ភអត់ថា អ្នកខាងក្រៅចូលមកធ្វើឲ្យខូចភាពសាមគ្គីភាពគ្នាក្នុងភូមិ?

ឈីន ៖ មានតើ ។

កុសល ៖ មាន?

ឈីន ៖ បើសព្វថ្ងៃទាមទារថា បើសិនជាអ្នកមកនៅចេញពីភូមិណាទៅភូមិណា គេឲ្យធ្វើសំបុត្រផ្ទេរ

កុសល ៖ សំខាន់ណាស់គួរតែធ្វើសំបុត្រផ្ទេរ?

ឈីន ៖ បាទ!

កុសល ៖ អ្នកចេញចូលនឹង គួរតែធ្វើសំបុត្រផ្ទេរ?

ឈីន ៖ បាទ! សព្វថ្ងៃចឹងឯង អ្នកសុំមកស្នាក់នៅ គេដាក់តែស្នាក់នៅ បើថាមកនៅឲ្យមានសំបុត្រ ផ្ទេរ ។ ស្នាក់នៅរយៈប៉ុន្មានថ្ងៃ រកស៊ី ដើរប៉ុន្មានខែៗ គេត្រូវតែមាន ។

កុសល ៖ ហេតុអីបានចាំបាច់ធ្វើមានសំបុត្រចឹង?

ឈីន ៖ ថាបញ្ជាក់ហេតុផល ។

កុសល ៖ ហេតុផលមកនៅ កុំឲ្យនៅតែពីសតែពាស?

ឈីន ៖ ម្យ៉ាងមនុស្សនៅនោះទៅ វាមិនត្រូវនឹងគេ ឬមនុស្សវាខូស ដល់កន្លែងណាមួយនឹង សុំ បញ្ជាក់សំបុត្រពីគេនឹង ឲ្យដឹងពីគណៈកម្មការភូមិគេនឹងឲ្យដឹងថា ។

កុសល ៖ កន្លងមកធ្លាប់មានបញ្ហានឹងទេ?

ឈីន ៖ មានបញ្ហាម៉េចៗ ឲ្យតែគេល្អពីដើមម៉េច យ៉ាងណាយ៉ាងណា ។

កុសល ៖ កន្លងមក មានបញ្ហានឹងទេ?

ឈីន ៖ អត់ទេ គ្រាន់ មានមកអត់សូវមាន ។

កុសល ៖ ចុះចំពោះរដ្ឋាភិបាលបច្ចុប្បន្ន ពូយល់ថារដ្ឋាភិបាលអាចផ្តល់នូវភាពកក់ក្តៅ និងភាពយុត្តិធម៌ដល់គ្រួសារលោកពូចំពោះលោកពូផ្ទាល់ដែរទេ បានកម្រិតណា ពី១តិច ៥ច្រើន?

ឈីន ៖ ទេ! បើនិយាយមិនចាំតែគ្រួសារខ្ញុំទេ គ្រួសារអ្នកដទៃក៏ដោយ គេផ្តល់ការទំនុកចិត្ត ទុកចិត្តរបស់រដ្ឋាភិបាលមកតាមរយៈវាល្អរបស់ខ្ញុំដែរ ។

កុសល ៖ ប៉ុន្មានភាគរយ ១០០ភាគរយ ឬក៏?

ឈីន ៖ ជិត១០០ភាគរយរបស់គាត់ដែរ ។

កុសល ៖ គ្រួសារពូខស្សាហ៍ទៅវត្តវ៉ាអីទេ?

ឈីន ៖ អត់ទេ ទៅពេលខែភ្ជុំនោះបានទៅទេ ។

កុសល ៖ ពូចូលរួមក្នុងការបំពេញកិច្ចការក្នុងស្រុកភូមិសកម្ម យល់ថាខ្លួនឯងជាសកម្មជនក្នុងភូមិ?

ឈីន ៖ ទេ! ខ្ញុំពីដើមមិញ ខ្ញុំធ្វើការសំនុំរបស់ខ្ញុំដែរ ខ្ញុំទើបសុំគេឈប់ ។

កុសល ៖ ពីមុនធ្វើអី នៅភូមិនេះ?

ឈីន ៖ អនុភូមិ ។

កុសល ៖ អនុភូមិ?

ឈីន ៖ ហើយខ្ញុំឈប់ហើយណា ។

កុសល ៖ មកដល់ឆ្នាំណាទើបឈប់?

ឈីន ៖ ឈប់បានប៉ុន្មានឆ្នាំទេ ៣ឆ្នាំ ៤ឆ្នាំដឹង ឈប់ ។

កុសល ៖ ឈប់២០០៥ ២០០៧ ២០០៨?

ឈីន ៖ ឈប់ខ្ញុំរៀបដាក់បេក្ខជនឲ្យអានេះ ក្មេង ដាក់ឲ្យបោះឆ្នោតជាប់អស់ខ្ញុំឈប់ ។

កុសល ៖ ចឹងពូជាសកម្មជនមួយដែរ?

ឈីន ៖ បាទ!

កុសល ៖ ចឹងខ្ញុំអាចដាក់ច្រើន ។ ពូយកចិត្តទុកដាក់អ្នកជិតខាង ជួយជ្រោមជ្រែងអ្នកជិតខាង បានកម្រិតច្រើន ពី១ដល់៥?

ឈីន ៖ ហ៎! ដែលខ្ញុំត្រង់គំនិត ត្រង់នយោបាយ ខ្ញុំមិនដែលទេ ខ្ញុំតែងតែណែនាំអប់រំ ខុសអីត្រូវអី ។ មិនឃើញតែនឹងភ្នែក ហើយខ្ញុំមិនចេះស្រែកប៉ុន្មានទេ អាខុសតែគេមិនស្តាប់ ។

កុសល ៖ ចឹងពូយកចិត្តទុកដាក់ចំពោះបញ្ហាសង្គម ជួយប្រជាជនច្រើន?

ឈីន ៖ បាទ!

កុសល ៖ គ្រួសារចំពោះការលើកឡើងចំពោះគ្រួសារលោកពូ?

ឈីន ៖ ធម្មតាគ្រួសារខ្ញុំ ។

កុសល ៖ យកចិត្តទុកដាក់ច្រើន ពូហ៊ានលះបង់ដើម្បីគ្រួសារច្រើនទេ?

ឈើន ៖ អឺ!លះបង់ច្រេីនហើយ ការងារនោះ ដូចជាគេថាការណែនាំការអប់រំ រកគំនិតនយោបាយជាបង្គោលនោះ សម្រាប់គ្រួសារខ្លួនឯង ហើយដើម្បីណែនាំគេ ទាល់តែខ្លួនយើងមើលឃើញខ្លួនយើងៗ ធ្វើខ្លួនយើងឲ្យគេមើលឃើញយើងច្បាស់ បានយើងណែនាំគេបាន ។ បើថាឲ្យយើងចេះតែមាត់ យើងអនុវត្តមិនបាន ប្រព្រឹត្តិមិនបាន គ្មានអ្នកណាគេតាមយើងទេ ។

កុសល ៖ តើពូយល់ថារដ្ឋាភិបាលបច្ចុប្បន្ននឹង អាចការពារប្រទេសជាតិយើងបានកម្រិតណា បូរណៈភាពដែនដីយើងបានដល់កម្រិតណា តិច ឬច្រើន?

ឈើន ៖ មិនដឹងរកដាក់ពាក្យនិយាយមិនកើត ។ ពីព្រោះខ្ញុំបានថាធានាដាក់អត់កើតពីព្រោះខ្ញុំនឹកឃើញថា ការប្រឹងប្រែង និងការយកចិត្តទុកដាក់ គ្រប់លក្ខណៈ គ្រប់ស្ថាប័នទាំងអស់ គឺបើនិយាយពីរឿងបោះឆ្នោតក៏ដោយ ពីរឿងអីក៏ដោយ ខ្ញុំថាក្រុមនឹងធ្វើអត់កើត យាប់ណាស់ ។ គាត់រៀបចំរចនាសម្ព័ន្ធ កសាងចលនាគ្រប់គ្រងអនុវត្តវាគ្រប់អស់ ចេញកន្លែងណាសុទ្ធតែការងារទាំងអស់ ។ ឃើញដំណើរតែពីតែពាស មើលងាយគេ ប្រហែលគេយ៉ាងអន់ នោះប្រធានអីនោះ គេសុទ្ធតែគំនិតគេបានដែរ មិនសូវចេះអក្សរក៏គេគ្រាន់ដែរ ។

កុសល ៖ ដូចសព្វថ្ងៃនឹង សំនួរដែលថា ខ្ញុំយល់ស្របតាមរាជរដ្ឋាភិបាលដោយឥតលក្ខខណ្ឌ ពូឯកភាពនឹងទេ?

ឈើន ៖ ចឹងទេ! មានអីឯកភាពតើ ។

កុសល ៖ ច្រើន តិច ច្រើន?

ឈើន ៖ ច្រើន ពីព្រោះឃើញការ ។

កុសល ៖ ចឹងលោកពូគាំទ្ររដ្ឋាភិបាលបច្ចុប្បន្ននឹង ដោយអស់ពីចិត្ត ពីថ្លើម?

ឈើន ៖ គាំទ្រនោះឯង ចុះខ្ញុំពីជំនាន់ណាមក ខ្ញុំមិនដែលឃើញទេ មិនថាម៉េចទេ ក្នុងសង្គមប៉ុន្មានជំនាន់ទៅហើយរឿងការអភិវឌ្ឍន៍ មិនដែលឃើញ ។

កុសល ៖ មិនដែលឃើញ ឥឡូវនេះអភិវឌ្ឍន៍ច្រើន ចង់និយាយចឹង?

ឈើន ៖ សព្វថ្ងៃ វាឃើញ វាមានទាំងទីក្រុង វាមានទាំងជនបទ ។

កុសល ៖ ពូរៀបរាប់ឲ្យដាក់ស្តែងបនចមើល យ៉ាងម៉េច មិនដែលឃើញៗអភិវឌ្ឍន៍ជាងមុនកន្លែងណា?

ឈីន ៈ វាល្អផង វាសមរម្យ កន្លែងណាដែលត្រូវសមរម្យៗ ។ ពីដើមផ្លូវអន្លង់វែងនេះ មួយជំនាន់ ខ្ញុំចុះមកនេះ ក៏មិនដឹងណាទេ មានតែផ្លូវរទេះទេ ហើយមានផ្លូវបារាំងរហុងៗតិចនោះឯង ។

កុសល ៈ ផ្លូវឆ្លងកាត់ភូមិស្រុក?

ឈីន ៈ អឺ! សុទ្ធតែផ្លូវរទេះ ។

កសល ៈ ល្អ?

ឈីន ៈ តិចៗនឹងពីមុន ហើយសព្វថ្ងៃយ៉ាងអន់ត្រឹមផ្លូវគ្រោះដែរ ។ ហើយបើខត្តរមានជ័យនេះ ខ្ញុំមកមុនដំបូង អឺ!ទាហានប្រហែលខ្លាទោបងាប់ ។ ខ្ញុំដល់មុនគេនេះឯងដាច់បឹតឈប់ ។

កុសល ៈ ចុះរឿងដីធ្លី រាល់ថ្ងៃនឹង ពូមានបារម្ភពីជនបរទេសដែលចូលមកស្រុកយើង? សំនួរសួរថាតើពូគាំទ្រឲ្យរាជរដ្ឋាភិបាលកាត់បន្ថយ នូវឥទ្ធិពលជនបរទេសដែរទេ? ជនបរទេសរួមទាំងពួកវៀតណាម ចិន ឲ្យតែបរទេសដែលចូលមករកស៊ី នៅក្តីរកស៊ីអីចឹង ។ តើលោកពូគាំទ្រកាត់បន្ថយឥទ្ធិពលពួកជនបរទេស?

ឈីន ៈ ចង់ឲ្យកាត់ពាក់កណ្តាល?

កុសល ៈ កាត់បន្ថយពួកហ្នឹង?

ឈីន ៈ បាទៗ ។

កុសល ៈ ហើយមូលហេតុអី?

ឈីន ៈ មូលហេតុខ្ញុំនឹកឃើញថា បើនៅច្រើន គេមានលុយច្រើន គេទិញដីយូរៗវាទៅយើងអ្នកក្រ សឹងដូចអត់មានសិទ្ធិ និយាយអត់ចេញ លុយតិច ត្រង់នេះមេខាងនេះ ។

កុសល ៈ តែពូបារម្ភថា ពួកនឹងមកវាយកដីយើងអស់?

ឈីន ៈ ខ្ញុំខ្លាចបារម្ភប៉ុននោះ ។

កុសល ៈ ពួកបរទេស ពូបារម្ភពួកណាជាងគេ ក្រុមថៃ ពួកវៀយណាម ពួកចិន ក្រុមណាដែលពូគិតថាគ្រោះថ្នាក់ជាងគេស្រុកយើង?

ឈីន ៈ ខ្ញុំថាចិនដូចវាមិនសូវអីទេ ។

កុសល ៈ ចិនមិនសូវអី?

ឈីន ៈ បាទ! ខ្ញុំថាដូចមិនសូវអី ។ ខ្ញុំព្រួយតែខាងនេះៗទេ ។

កុសល ៈ យួន និងថៃ?

ឈីន ៈ បាទ! ខ្លាចប៉ុននោះ អានេះមិនចោទគេទេ ។

កុសល ៈ ពូអត់បារម្ភរឿងពួកចិនមកទេ អត់បារម្ភ?

ឈីន ៖ មិនសូវបារម្ភ ។

កុសល ៖ ហេតុអី?

ឈីន ៖ ព្រោះតែវាហានមកយកអានេះ វាគន្ធងប្រទេសគេមួយ វាពិបាក ។

កុសល ៖ អី! គន្ធងប្រទេសមួយ វៀតណាម ចិន នៅឆ្ងាយ?

ឈីន ៖ ហ្នឹងហើយវាពិបាក បាទ!រំលងជាតិយើង រំលងគេមួយបាត់ហើយ ត្រូវជួបឧបសគ្គច្រើន មកនេះមានខ្វះអីស្មាចប៉ុន្មានម៉ែត្រនេះហើយ ។

កុសល ៖ ចុះលោកពូយល់ថា ប្រជាពលរដ្ឋល្អម្នាក់គួរតែការពារប្រទេសជាតិឲ្យមានកិត្តិនាម និងកេរ្តិ៍ឈ្មោះរបស់ជាតិយើងនៅក្នុងតំបន់ដែរទេ? ថាតើយើងគួរតែធ្វើគ្រប់បែបយ៉ាងដើម្បីការពារបូរណភាពដែនដី យើង?

ឈីន ៖ ទេ! ខ្ញុំតាំងពីនោះមក ខ្ញុំថាខ្ញុំធ្វើតាមកម្រិតខ្ញុំរហូតបាន ដល់ខ្ញុំឈប់នេះក៏ឈប់រឿនការងារបម្រើអន្តភាព បម្រើជាតិដែលខ្ញុំឈប់ធ្វើមេក្រុមឈប់ធ្វើអី ។ ឈប់ដូចខ្ញុំសុំដាកស្តែងអត់មានខឹង បែកចាយស៊ីលើស៊ីក្រោមអន់ចិត្តអីអត់ទេ ត្រង់ម៉ង ។

កុសល ៖ ចឹងលោកពូបម្រើជាតិស្មោះស្ម័គ្រអស់មួយជីវិត?

ឈីន ៖ បាទ! ស្មោះស្ម័គ្រ ខ្ញុំឈប់ក៏អត់មានតូចចិត្ត ប្រជុំ២-៣សារ ទម្រាំបានគេសួរមតិក្នុងក្រុមប្រឹក្សាបានគេឯកភាពសម្រេចឲ្យឈប់ៗ ។ គេសួរយោបល់ថា ឲ្យអ៊ំឈប់ក្រែងគាត់មានទស្សនៈខឹងអី អន់ចិត្តនឹងអ្នកនោះ បែកអីទឹកខ្វះអីម៉េច ធ្វើការងារឲ្យអន់ចិត្តអន់ថ្លើម ។ បានគេឯកភាពមក ចេញមកទាំងអស់ បានក្រែងថាឯកភាពតែ២-៣នាក់ឯកភាពខុបខិតខឹង ខ្លាចខ្ញុំឈប់ ។ ខ្ញុំអត់ទេ អត់ខឹងបងប្អូន ព្រោះភ្នែកខ្ញុំយ៉ាប់ហើយសព្វថ្ងៃនេះ មើលសំបុត្រមើលអីយ៉ាប់ហើយ ពាក់វ៉ែនតាមើលបានមួយសន្ទុះទេ នឹកទៅវិញទៀតហើយ ។

កុសល ៖ ចុះពេលជម្លោះថ្មីៗនេះជាមួយប្រទេសថៃនេះ ពូយល់យ៉ាងណាដែរ?

ឈីន ៖ ជម្លោះថ្មីៗនេះ ។

កុសល ៖ ចុះពូមានកូនប្រុសធ្វើទាហានទេ?

ឈីន ៖ អត់ទេ ។

កុសល ៖ យើញបងទាហានមិញពីណាគេ?

ឈីន ៖ អូ! កូនក្មេងទាហាន វាស្នាក់នៅយូរណាស់ហើយ ដល់ពេលវាផុតការងារទាហានវាមកដេកហូបនេះ ដូចឪពុកធ នៅខ្សែងសៀមរាប ។

កុសល ៖ ចុះបើសិនជាថៃហ្នឹងវាចូលមកយកប្រាសាទព្រះវិហារ ពូគិតយ៉ាងណា?

ឈីន ៖ គិតម៉េច បើចិត្តខ្ញុំ បើទៅដល់ធ្វើមិនកើតទេថាតែមាត់ថាចុះ ខ្ញុំថាមិនចង់ឲ្យយកបាន ។

កុសល ៖ ធ្វើយ៉ាងណាទៅចឹង? ដូចថាពូជាទាហានម្នាក់ ធ្លាប់ធ្វើទាហានការពារព្រំដែន ដល់ឥឡូវពូ ថាព្រំដែន?

ឈឹន ៖ ហ៎! ទស្សនៈខ្ញុំឃើញគេផ្អើលខ្លះរៀបអីៗ បើខ្ញុំអត់ទេ មិនបាច់ទេ វាមិនមានដូចជំនាន់ យើងយួននិងខ្មែរៗនិងខ្មែរទេ ពីមុនពីក្រោយនៅតែយើងនៅបានៗ បាននៅណានោះ ផ្អើលទៅផ្អើលមកៗ ថាមិនសំនុំឲ្យកូនជញ្ជូនទៅឲ្យផុតទៅ ខ្ជួនឯងនៅចងក្រងគ្នា៨,៥,១០ នាក់បានលើកនេះនៅបណ្ដោយៗ សង្កេតមេលចាំមើលវានៅខាងប៉ុនណា មេគេឲ្យកាំ ភ្លើងអីទៀត រំកិលដាក់មីន មែនអត់ខ្លាចទេ ប្រកភ្នំដងរែកស្គាល់ប្រហែលខ្ញុំៗ

កុសល ៖ ស្គាល់ច្បាស់?

ឈឹន ៖ ច្បាស់ណាស់ ឯងមកផ្លូវនេះ អញស្ទាក់ផ្លូវនោះឥឡូវហើយៗ

កុសល ៖ នៅតំបន់នេះពូដើរសឹកអស់ហើយ ស្គាល់អស់?

ឈឹន ៖ បាទ! មានអីខ្ញុំខស្សាហ៍ព្យាយាមទាក់ទងដែរមេទាហានសួរ សំនេរសំណាល សួរតែរហូត ដល់គេឆ្លើយទៅប៉ាន់ស្មានៗ កូនទាហានបើសិនជាមានបញ្ហាវាអាចទុកចិត្តយ៉ាងម៉េចៗ ខ្ញុំ សួរធ្វើដូចឯងអ្នកសម្ភាសន៍ដែលនោះៗ ពេលចូលមកម្ដងៗ ពេលផ្ទុះមកពីព្រះវិហារៗ គេថាវាទាហានមិនបាន១០០ភាគរយទាំងអស់ទេ ដូចឃើញស្រេចហើយ ទាហានសព្វថ្ងៃ ច្រើនស៊ីប្រាក់ផង ហើយគ្នាមិនដែលទាន់បានប្រឡូកចលនាសង្រ្គាម គ្រាន់បានរៀនបច្ចេក ទេសទៅតាមយុទ្ធវិធីនេះឯងៗ ដល់អាប្រឡូកដាក់ស្ដែងនៅឡើយៗ នេះសំខាន់ មាន ឃើញបងពីម តា ហ៊ី នៅព្រះវិហារៗ

កុសល ៖ បាទ! ឥឡូវនៅព្រះវិហារ?

ឈឹន ៖ នឹងហ៊ុន សែន ទុកចិត្តពេញដឹកទៅហើយ ហ្នឹងហើយសុទ្ធតែមេចាស់ៗ ខ្នាតខ្ញុំខ្នាតអីនេះ សុទ្ធតែកាន់ដេការអីនៅបញ្ជាផ្ទាល់ៗទាំងអស់ៗ

កុសល ៖ បាទ! ពួកគាត់មើលភូមិសាស្រ្តគេឲ្យទៅវ៉ៃនឹង បានពួកថៃខ្លាចពួកនឹង?

ឈឹន ៖ លេងពួកនោះ ឆុលៗនេះៗ

កុសល ៖ គាត់ស្គាល់ភូមិសាស្រ្តច្បាស់?

ឈឹន ៖ ចុះស្គាល់ៗប៉ុនគេដឹងល្បិច គេដឹងបច្ចេកទេសង្រ្គាម ថាមិនអួតទេ ប៉ុនគេដឹងៗ ផ្ទុះតែមួយ ព្រឹមគេដឹងចំនុចថារបៀបម៉េច ត្រូវវ៉ៃត្រង់ចំនុចណា ហើយត្រូវយកកម្លាំងដាក់ត្រង់ណា ត្រូវទប់ត្រង់ណាៗ

កុសល ៖ ចឹងដោយសារធ្លាប់ធ្វើកិច្ចការជាមួយពួកសៀមពីមុនមកយើងដឹងៗ ថាពួកនឹងល្បិចយ៉ាង ម៉េច ទីតាំងភូមិសាស្រ្ត?

ឈឺន ៖ អ! បើធ្វើជាមួយសៀម ខ្ញុំមិនថាម៉េចទេ ខ្ញុំថាសៀមនេះមិនងាយរត់ផ្ដាស់ទេ បនបើបាញ់ស្រួលទៀត ហើយគ្រាប់ផ្លោងស៊ូបានស៊ូៗមនបាន ចុះខ្ញុំវ៉ៃឡើងមិនចេះតិចដងពីជំនាន់៧៦ ៧៧ វ៉ៃថៃមិនចេះស្មើរចូលដល់ផ្សារទៅដល់អីនោះមិនធម្មតាណា ពេញដីកបុកមិនរត់ទេណាគ្នា១០នាក់ ៥នាក់គរនៅនោះហើយ ។ ហើយបុកមិនងាយទៅទៀត ងាប់ៗទៅអូ! ពូកែក្រាញ ប៉ុនចាំមើលយកដាក់ឆ្អឹងជំនីរ បុកពីក្រោយដីងៗទៅបណ្ដោយ គេដឹងក្បួនបាត់ទៅហើយ ។ ខ្ញុំដឹងល្បិចអស់ហើយ គេអត់រត់ចោលគ្នា បើថាងាប់ៗកុំឲ្យម៉ែឪប្រណែនងាប់ៗទាំងអស់គ្នា អត់ដូចខ្មែរយើងទេ ។

កុសល ៖ ខ្ញុំជិតចប់ហើយចុងក្រោយខ្ញុំសួរ ធ្វើម៉េចទៅកុំឲ្យមានរបបពាឆ្នាំ កើតឡើងនៅជំនាន់ក្រោយទៀត? ដូចឃើញហាក់ដូចជា តាមស្ដាប់មើលសាច់រឿងមាន២ អ្នកតស៊ូ ការពារនឹង គឺបាត់បង់កូនចៅជំនាន់ក្រោយ ដូចពូផ្ទាល់បាត់បង់ បែកបាក់ឪពុកម្ដាយ ធ្វើសង្គ្រាមនៅជួរមុខនេះ ការពារប្រទេស ស្រាប់តែគ្មានដឹងថាអ្នកនៅធ្វើខុសនៅក្រោយ ។ ចង់មិនចង់រឿងនឹងកើតឡើងចឹងយើងធ្វើម៉េចទប់ស្កាត់អំពើនឹងកុំឲ្យកើតឡើងតទៀតនៅពេលថ្ងៃក្រោយ?

ឈឺន ៖ ខ្ញុំថាដូចមិនកើតទេ ។

កុសល ៖ មិនកើតហេតុអី?

ឈ់ន ៖ បានថាមិនកើត ពីព្រោះវាបានរីកចំរើនល្អហើយ ទាំងការអភិវឌ្ឍន៍ជនបទ ហើយប្រជាជនមិនធ្លាប់គ្រាន់ក៏គ្រាន់ មិនមានថាហ៊ុន សែន ឬក៏គណៈស្រុកចៅហ្វាយស្រុក យករបស់មកចែកផ្ទាល់ទេ ។ គ្រាន់តែរាយផែនការគម្រោងការរៀបចំមានផ្លូវមានស្ពានចុះហើយ បើធំទូលាយរឿងបងប្អូនរកស៊ី ម្ល៉ោះហើយមានទីផ្សារថ្លៃថោក ដល់ហើយប្រជាជនចេះតែប្រឹងរកឃើញអាខ្លះពីមុនមិញ កង់យូរៗចង់បាត់កង់អស់ហើយផ្ទះមួយៗ នៅតែម៉ូតូ ។ អ្នកមិនធ្លាប់ ។

កុសល ៖ រឿងអីចូលព្រៃទៀត ជីវភាព?

ឈឺន ៖ អ្នកណាដែលចង់ ។

កុសល ៖ ចុះទាក់ទងនឹងប្រព័ន្ធយុត្តិធម៌ស្រុកយើង តើលោកពូជឿជាក់លើប្រព័ន្ធតុលាការយុត្តិធម៌ស្រុកយើងថាមានប្រសិទ្ធិភាពដែរទេ?

ឈឺន ៖ ខ្ញុំជឿថា មាន ។

កុសល ៖ ត្រឹមកម្រិតណា?

ឈឺន ៖ ៥០ ៦០ ៧០ភាគរយដែរ ដើម្បីហៅថាយុត្តិធម៌ពិត ។

កុសល ៖ ចុះចំពោះរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមសព្វថ្ងៃនឹង ដូចថាមានធ្វើនៅស្រុកខ្មែរ ពូយល់ថាមានប្រយោជន៍ទេ?

ឈីន ៖ មាន ។

កុសល ៖ ហេតុអីបានមានប្រយោជន៍ ដល់ត្រឹមកម្រិតណា?

ឈីន ៖ ជំនួយដល់ជាតិ ពីព្រោះបរទេសហៅថាជំនួយថវិកាមក ។

កុសល ៖ គេឲ្យថវិកាមក?

ឈីន ៖ រៀបចំផែនការកាត់ទោស ហើយនឹងអាចមានកម្រៃសល់ប្រជាជន ឬក៏ធ្វើអីត្រង់ណាខ្លះមិនថាចុះ ។

កុសល ៖ ចុះក្រៅពីនឹងមានអីទៀត ក្រៅពីលុយកាក់ អាចមានផលប្រយោជន៍ល្អខ្លះ អាក្រក់អ្វីខ្លះ?

ឈីន ៖ ក្រៅពីលុយកាក់មានស្អី ។

កុសល ៖ បាទ!តុលាការនឹងដូចនាំយកថវិកាមក ប៉ុន្តែក្រៅពីនឹងមានអីទៀត មានប្រយោជន៍អីទៀតដែលមានខ្មែរចូលរួម?

ឈីន ៖ ផលប្រយោជន៍ដើម្បីខ្មែរចូលរួមផង ហើយគ្រប់ប្រទេសទាំងអស់ក៏គេមើលឃើញយើងថាយើងពឹងអន្តរជាតិ ហើយទស្សនៈគឺខ្លួនឯង ឲ្យអន្តរជាតិមើលហើយជឿជាក់ថា ខ្មែរស្វែងយល់ហៅថាយុត្តិធម៌ ។

កុសល ៖ ចុះពូជឿថាតុលាការនឹងអាចមានឥទ្ធិពលដូចថា ទប់ស្កាត់កុំឲ្យមានរបបនឹង កើតឡើងតទៅទៀតទេ មេដឹកនាំខ្មែរយើងជំនាន់នឹងកុំឲ្យប្រព្រឹត្តអំពើនឹងតទៅទៀត?

ឈីន ៖ ខ្ញុំថាដូចទប់បាន ។

កុសល ៖ អាចបានកម្រិតណា ពី១ដល់៥?

ឈីន ៖ អាច៥ ។

កុសល ៖ ហេតុអីពូ? ហេតុអីបានអាចទប់ស្កាតបាន?

ឈីន ៖ បានទប់ស្កាត់បានម៉េច បើមានអានោះហើយ ធ្វើម៉េចទៅរួច ។

កុសល ៖ ខ្ញុំមិនទាន់យល់ថាហេតុអី គ្រាន់តែតុលាការមួយអាចទប់ស្កាត់អំពើនឹង កុំឲ្យកើតមានឡើងទៀតបាន?

ឈីន ៖ បើប្រព្រឹត្តទៅគេទប់ស្កាត់ៗដោយមានអ្នកបង្ហើបចលនាអីនេះនោះ ដល់ភាគីខាងនោះមកដឹងទៅគេរៀបចំ ហើយទៅនិយាយ ចុះហើយអត់ហ៊ានបានទេ ។

កុសល ៖ ចឹងធ្វើឲ្យមនុស្សខ្លាច?

ឈីន ៖ មនុស្សខ្លាច ។

កុសល ៖ សំនួរចុងក្រោយទាក់ទងនឹងការផ្សះផ្សា ពូយល់ថា តើប្រជាជនកម្ពុជាគួរតែគិតយ៉ាងដូចរាល់ពេលដែលពួកគាត់ឮអំពីរបបពាឆ្នាំ របបកម្ពុជាប្រជាធិបតេយ្យ? ទី១ទប់កំហឹងក្នុងចិត្តពូឲ្យយោបល់យ៉ាងម៉េច ចំពោះអ្នកដែលរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ? ពេលដែលគេគិតដល់របបនោះ ពូឲ្យយោបល់យ៉ាងម៉េច? ទប់កំហឹងក្នុងចិត្ត ។

ឈឺន ៖ មិនឲ្យអាក់អន់ស្រពន់ចិត្តចំពោះគេកាត់ក្ដី ។

កុសល ៖ ចំពោះអ្វីដែលបានកើតឡើង ព្រោះអ្នកខ្លះគិតដល់របបខ្មែរក្រហមចេះតែខឹងច្រឡោតគោតតូងរកតែកាប់ចាក់អីចឹង ។ ចឹងចំពោះលោកពូវិញ ពូយល់ថា ដើម្បីការផ្សះផ្សា តើប្រជាជនយើងគួរតែធ្វើយ៉ាងម៉េច? ទី១ទប់កំហឹងក្នុងចិត្ត ពេលឮគិតពីរបបខ្មែរក្រហមយើងគួរតែទប់កំហឹងក្នុងចិត្ត? ដល់កម្រិតណា?

ឈឺន ៖ ខ្ញុំយល់ បើខ្ញុំប៉ុន់ ហ៎! គេក៏យល់យ៉ាងនឹងកំហុសនិយាយតូចធំចេះចុះ ហៅថាអត់មាត់អត់អី វិភាគពិចារណាដូចខ្ញុំចឹង ធ្វើម៉េចបើវាប្រែប្រួលតាមជំនាន់សង្គមកាត់ទោស ក៏ជាអីនោះដើម្បីស្វែងយល់យុត្តិធម៌របស់គេហើយ គេអ្នកធ្វើការ ។ ហើយយើងមិនមានពិបាកទៅខ្វះអីនឹងខ្វាចធ្វើមកយើង ។ យើងវាប៉ះដែរ តែយើងអត់ប្រព្រឹត្តនោះ យើងគ្រាន់តែនៅក្នុងសង្គមមិនថាចុះ ។ មេះហើយគេនៅធម្មតាទៅ ។

កុសល ៖ ពូមានអារម្មណ៍សោកស្ដាយ ដែលពាក់ព័ន្ធនឹងរបបនឹង?

ឈឺន ៖ ពាក់ព័ន្ធពីជំនាន់មុនអត់ទេ មិននេះទេ ព្រោះសោកស្ដាយម៉េច បើគេឲ្យយើងធ្វើទៅហើយសោកស្ដាយថាស្ដាយខ្លួន ក៏កាលនោះយើងអត់ដឹងរឿងអីនេះណាអត់ ដល់តែមួយទៅហើយ បើថាពីរទៅគ្រាន់ស្ដាយមកនេះខុសបាត់ ។

កុសល ៖ ចឹងយើងគួរតែបំភ្លេចចោលរបបនឹង ពូឯកភាព?

ឈឺន ៖ ខ្ញុំហ៎!

កុសល ៖ យើងគរតែបំភ្លេចចោលដើម្បីផ្សះផ្សា?

ឈឺន ៖ ខ្ញុំឯកភាពដែរតើ ។

កុសល ៖ ច្រើន?

ឈឺន ៖ ហ៎! ច្រើនដែរ ។

កុសល ៖ យើងគួរតែគិតពីអនាគតជំនួសវិញ គិតពីរឿងផ្សេងជំនួសវិញ?

ឈឺន ៖ បាទ! គិតពីអ្វីៗដែលផលប្រយោជន៍ល្អច្រើន ។

កុសល ៖ ដូចថារឿងខាងលើនឹងកន្លងផុតទៅហើយ មិនគួរគិតទៅមុខទៀត?

ឈឹន ៖ កន្លងផុតទៅហើយ ។ ចុះបងខ្ញុំស្លាប់ជំនាន់នោះ ខ្ញុំចេះខឹងម្ដរមៅ ស្រាវជ្រាវ អានិយាយ អញខឹង ។ ប៉ុនមិនដឹងធ្វើយ៉ាងម៉េច ពីសង្គមត្រូវចុះឯង ដែលសង្គមវាទៅចុះឯងៗបត់តាមដូចខ្ញុំ បើបត់ដូចខ្ញុំរស់បាត់ហើយ ។

កុសល ៖ ចឹងពូអត់មានកំហឹងអីទេ?

ឈឹន ៖ អត់ទេ គ្មានកំហឹងទេ ខ្ញុំថាចុះខ្ញុំថារួចហើយខ្ញុំថាមិនទាន់ចេញធ្វើទាហាន ។

កសល ៖ យើងគួរតែអត់ឱនទោសឲ្យគ្នាទៅវិញទៅមក?

ឈឹន ៖ បាទ! បងឯងនេះមាត់ម៉ាក់នេះ ហើយទាំងបងប្អូនញាតិតែម៉ាកនេះ សម័យនេះបងឯងមិនស្រួលងាប់ ។ ដែលខ្ញុំចេញមកមិនទាន់បាន៣ឆ្នាំ ងាប់បាត់ ។ ត្រីកំភ្លាញដោយសារតែមាត់ តើមាត់ គេបាចយកទៅស្ងោរ ប៉ុនខ្លួននោះអត់បានប្រព្រឹត្តសោះ ប៉ុនមាត់ ។

កុសល ៖ ចុះលោកពូជឿលើបុណ្យបាប កម្មពៀរដែរទេ?

ឈឹន ៖ ជឿដែរតើ ។

កុសល ៖ តិច ឬក៏ច្រើន?

ឈឹន ៖ ពាក់កណ្ដាល ។

កុសល ៖ ពូមានអីបន្ថែមដូចថាចង់ណែនាំអ្នកជំនាន់ក្រោយដូចជាខ្ញុំ ដែលជាអ្នកស្រាវជ្រាវពីប្រវត្តិសាស្ត្រជំនាន់នឹង ពូមានដូចថាដំបូន្មានអីខ្លះចុងក្រោយដែលចង់ប្រាប់ខ្ញុំ?

ឈឹន ៖ ទេ! ខ្ញុំវាមិនមានអីទេ គ្រាន់តែថាផ្ដាំផ្ញើទៅក្មួយដែលបានរៀនសូត្រ ចេះចាំ បានជំនួសសង្គម ជំនួសឪពុកម្ដាយទុកចិត្តធ្វើម៉េច តែក្មួយប្រឹងប្រែងបន្តការដឹកនាំផ្នែកនយោបាយនិងបច្ចេកទេស បំភ្លឺដល់ប្អូនៗតូចៗដែលគ្នាវានៅល្ងង់ខ្លៅ គឺវាសំខាន់ដូចជាយុវវ័យ ដើររកព័ត៌មាន ផ្សព្វផ្សាយព័ត៌មានកើនរំលឹកពីរឿងយុវវ័យធ្វើម៉េច ឲ្យគ្រប់តាមភូមិតាមឃុំឲ្យបានដឹងទៅគាត់ ដើម្បីកាត់បន្ថយការវង្វេងឆ្លក់ទៅតាមមិត្តភ័ក្តមិនសមហេតុសមផល ទៅតាមថ្នាំតាមអី គ្មានអីទេ ខ្ញុំមានតែប៉ុននេះ ។

កុសល ៖ បាទ! ខ្ញុំអរគុណពូច្រើន ។

«ចប់»